# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ROYAL UNIVERSITY OF PHNOM PENH

# បញ្ហាប្រឈមនៃការគ្រប់គ្រង និង ការអនុវត្តថវិកាកម្មវិធី(PB) នៅសាលាបឋមសិក្សាក្រាំងធ្នង
# CHALLENGES OF PROGRAMME BUDGETING MANAGEMENT AND IMPLEMENTATION AT KRAING THNONG PRIMARY SCHOOL

របាយការណ៍ស្រាវជ្រាវ

ដាក់ជូនក្នុងចំណែកមួយសម្រាប់ការបំពេញតម្រូវការនៃការបញ្ចប់

បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ គ្រប់គ្រងនិងរៀបចំផែនការអប់រំ

**អឿង ចំរុង**

**មេសា ២០១២**

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ROYAL UNIVERSITY OF PHNOM PENH

# បញ្ហាប្រឈមនៃការគ្រប់គ្រង និង
# ការអនុវត្តថវិកាកម្មវិធី(PB) នៅសាលាបឋមសិក្សាក្រាំងធ្នង
# CHALLENGES OF PROGRAMME BUDGETING MANAGEMENT AND IMPLEMENTATION AT KRAING THNONG PRIMARY SCHOOL

របាយការណ៍ស្រាវជ្រាវ
ដាក់ជូនក្នុងចំណែកមួយសម្រាប់ការបំពេញតម្រូវការនៃការបញ្ចប់
បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ គ្រប់គ្រងនិងរៀបចំផែនការអប់រំ

**អឿន ចំរុង**

**គណៈកម្មការត្រួតពិនិត្យ៖** លោកបណ្ឌិត **ឌី សមស៊ីដេត**
លោក **ឆាម រតនៈ**

**មេសា ២០១២**

# មូលន័យសង្ខេប


ស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(២០០៥-២០១៥) រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់ក្រសួងអាទិភាពចំនួន ៧ ដែលរួមមាន៖ ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងយុត្តិធម៌ ក្រសួងអភិវឌ្ឍជនបទ ក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា ឲ្យអនុវត្តសាកល្បងនូវប្រភេទថវិកាកម្មវិធីសកម្មភាពអាទិភាព(PAP) ឬថវិកាកម្មវិធី(PB) ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ បន្ទាប់មកក្នុងឆ្នាំ២០០៨ ការអនុវត្តសាកល្បងនូវប្រភេទថវិកានេះត្រូវបានពង្រីកវិសាលភាពដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

វិស័យអប់រំ គឺជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពទាំង៨ដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់។ ការដាក់ឲ្យអនុវត្តសាកល្បងនូវប្រភេទថវិកាទាំងនេះនៅក្រសួងអប់រំ យុវជន និងកីឡាគឺក្នុងគោលបំណងកាត់បន្ថយបន្ទុកចំណាយក្រៅផ្លូវការរបស់មាតាបិតាសិស្ស បង្កើនអត្រាឡើងថ្នាក់ និងកាត់បន្ថយអត្រាត្រួតថ្នាក់របស់សិស្សពីថ្នាក់ទី ១ ដល់ទី ៦។ ការអនុវត្តសាកល្បងថវិកាPAP នៅក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្តើមពីឆ្នាំ២០០០ ដល់ឆ្នាំ ២០០៦ ហើយចាប់ពីឆ្នាំ២០០៧ រហូតដល់បច្ចុប្បន្ននេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្តូរយុទ្ធវិធីប្រែក្លាយការអនុវត្តថវិកាPAP មកជាការអនុវត្តថវិកាPB វិញ។

ការអនុវត្តថវិកាទាំងពីរប្រភេទនេះមានលក្ខណៈខុសពីគ្នា ដែលជាហេតុនាំលទ្ធផលនៃការអនុវត្តថវិកាPB នៅក្រសួងអប់រំ យុវជន និងកីឡាតាំងពីឆ្នាំដំបូងរហូតដល់បច្ចុប្បន្ន មិនទាន់ឆ្លើយតបតាមទិសដៅ និងសូចនាកររបស់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្រសួងអប់រំ យុវជន និងកីឡាបានកំណត់នៅឡើយទេ ពីព្រោះលក្ខខណ្ឌនៃការផ្តល់មូលនិធិប្បទានពីដៃគូអភិវឌ្ឍមួយចំនួន គឺផ្អែកលើលទ្ធផលនៃការអនុវត្តថវិកា ហើយដែលថវិកាកម្មវិធីនេះត្រូវបានបែងចែកមួយផ្នែកធំ សម្រាប់ជួយឧបត្ថម្ភដល់ការអនុវត្តសកម្មភាពដំណើរការសាលារៀន ដូច្នេះសាលារៀនគឺជាអ្នកអនុវត្តសកម្មភាពផ្ទាល់។

# លិខិតដឹកនាំការស្រាវជ្រាវរបស់សាស្ត្រាចារ្យដឹកនាំ

កម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ
ឈ្មោះបេក្ខជន៖ អឿង ចំរុង

ចំណងជើងរបាយការណ៍ស្រាវជ្រាវ៖ បញ្ហាប្រឈមនៃការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅសាលាបឋមសិក្សាក្រាំងធ្នុង។

សូមបញ្ជាក់ថា ការស្រាវជ្រាវដែលជារបាយការណ៍ស្រាវជ្រាវសម្រាប់បំពេញលក្ខខណ្ឌយកសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំដែលមានចំណងជើងដូចខាងលើនេះ ត្រូវបានធ្វើដោយបេក្ខនារីដែលមានឈ្មោះខាងលើ ក្រោមការដឹកនាំរបស់ខ្ញុំផ្ទាល់។ ខ្លឹមសាររបាយការណ៍ស្រាវជ្រាវនេះពុំទាន់មាននៅក្នុងការសរសេរយកសញ្ញាបត្រកម្រិតណាមួយនៅឡើយ។ ក្នុងការរៀបចំរបាយការណ៍ស្រាវជ្រាវនេះ ខ្ញុំបានដឹកនាំនូវផ្នែកខាងក្រោមនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២
**ហត្ថលេខាសាស្ត្រាចារ្យដឹកនាំ**

**និត ប៊ុនឡៃ**

## លិខិតរបស់បេក្ខជន

នាងខ្ញុំ អឿង ចំរុង សូមបញ្ជាក់ថា របាយការណ៍ស្រាវជ្រាវដែលមានចំណងជើងថា បញ្ហាប្រឈមនៃការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធី(PB) នៅសាលាបឋមសិក្សាក្រាំងធ្នុង សម្រាប់បំពេញលក្ខខណ្ឌយកសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់យកសញ្ញាបត្រនៅសាកលវិទ្យាល័យនេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតិពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២

**ហត្ថលេខាបេក្ខជន**

**អឿង ចំរុង**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២

**ហត្ថលេខាសាស្ត្រាចារ្យដឹកនាំ**

**និត ប៊ុនឡៃ**

កម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ

ចំណងជើងរបាយការណ៍ស្រាវជ្រាវ៖ បញ្ហាប្រឈមនៃការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅសាលាបឋមសិក្សាក្រាំងធ្នុង។

របាយការណ៍ស្រាវជ្រាវដាក់ជូនគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃដោយ អឿង ចំរុង

មូលវិចារណ៍៖

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២

**ប្រធានគណៈកម្មការវាយតម្លៃ** **អ្នកវាយតម្លៃក្នុងសាកលវិទ្យាល័យ** **អ្នកវាយតម្លៃក្រៅសាកលវិទ្យាល័យ**

# លិខិតថ្លែងអំណរគុណ

ជាបឋម សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) ដែលបានផ្តល់អាហារូបករណ៍សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំនេះ។ ជាមួយគ្នានេះដែរ សូមអរគុណចំពោះនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡាដែលបានសម្របសម្រួល និងបង្កលក្ខណៈរៀបចំឲ្យមានកម្មវិធីអាហារូបករណ៍នេះឡើង និងបានផ្តល់ឱកាស ការសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ គ្រប់គ្រងនិងរៀបចំផែនការអប់រំកន្លងមកនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ក្រៅពីនេះ សូមថ្លែងអំណរគុណចំពោះលោកបណ្ឌិត និងសាស្ត្រាចារ្យទាំងអស់ដែលបង្រៀននៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ គ្រប់គ្រងនិងរៀបចំផែនការអប់រំនៃសាកលវិទ្យា-ល័យភូមិន្ទភ្នំពេញដែលលោកបានខិតខំប្រឹងប្រែងបង្រៀន ពន្យល់ណែនាំ តាំងពីចាប់ផ្តើមរហូតដល់បញ្ចប់។ ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកបណ្ឌិត **និត ប៊ុនឡៃ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ខិតខំពន្យល់ណែនាំនិងត្រួសត្រាយផ្លូវ ក្នុងកិច្ចការស្រាវជ្រាវនេះ ប្រសិនបើពុំបានទទួលការណែនាំ ព្រមជាមួយការជួយជ្រោមជ្រែងពីលោកគ្រូទេ របាយ-ការណ៍ស្រាវជ្រាវនេះពិតជាពុំអាចបញ្ចប់បានជាស្ថាពរដែរ។

បន្ថែមពីលើនេះ សូមថ្លែងអំណរគុណនូវឧបការគុណដ៏លើសលប់ដល់អ្នកមានគុណទាំងទ្វេ ព្រមទាំងម្តាយមីងជាទីគោរពដ៏ខ្ពង់ខ្ពស់ ដែលលោកទាំងបីចិញ្ចឹមបីបាច់ថែរក្សា ឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្តក្នុងការសិក្សារៀនសូត្រតាំងពីតូចរហូតដល់បច្ចុប្បន្ន ដោយមិនគិតពីការលំបាកនឿយហត់ ឬត្អូចត្អែរអ្វីឡើយ។ គុណូបការៈរបស់លោកអ្នកមានគុណទាំងបី ក្នុងមួយជីវិតនេះមិនអាចតបស្នងសងគុណអស់ឡើយ គឺមានតែម្រាមដៃដប់សូមបួងសួងដល់វត្ថុសក្ដិសិទ្ធក្នុងលោកសូមឲ្យលោកទាំងបីមានសុខភាពល្អ កុំឲ្យមានរោគាមកបៀតបៀន។ ជាងនេះទៅទៀត សូមអរគុណដល់ប្អូនៗជាទីស្រឡាញ់រាប់អាន ព្រមទាំងគ្រួសារជាទីគោរពស្រឡាញ់ ដែលតែងតែជួយឧបត្ថម្ភគាំទ្រ ជ្រោមជ្រែង លើកទឹកចិត្ត និងផ្តល់ជាគំនិត គ្រប់ពេលវេលា។

លើសពីនេះ សូមអរគុណដល់មិត្តភក្តិទាំងអស់ដែលបានផ្តល់ជាកម្លាំងកាយចិត្ត ជួយផ្តល់ជាមតិយោបល់កែលម្អរាល់កំហុសឆ្គងក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវនេះ ដើម្បីឲ្យការសិក្សានេះប្រព្រឹត្តទៅបានដោយរលូន។

ជាទីបញ្ចប់ សូមជូនពរដល់លោកបណ្ឌិត លោកសាស្ត្រាចារ្យ អ្នកមានគុណ ព្រមទាំងក្រុមគ្រួសារ និងមិត្តភក្តិទាំងអស់ មានសុខភាពល្អ ជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ និងទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ និងនៅគ្រប់ទីកន្លែងកុំបីអាក់ខានឡើយ។

# មាតិកា


**ទំព័រ**

មូលន័យសង្ខេប (i)

លិខិតដឹកនាំការស្រាវជ្រាវរបស់សាស្ត្រាចារ្យដឹកនាំ (ii)

លិខិតរបស់បេក្ខជន (iii)

លិខិតថ្លែងអំណរគុណ (v)

មាតិកា (vi)

បញ្ជីអក្សរកាត់ (viii)

**ជំពូកទី ១ សេចក្តីផ្តើម** (១)

១.១ សារបាន (១)

១.២ ការកំណត់បញ្ហា (៤)

១.៣ គោលបំណងនៃការសិក្សាស្រាវជ្រាវ (៥)

១.៤ សំណួរសម្រាប់ការសិក្សាស្រាវជ្រាវ (៥)

១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ (៦)

១.៦ គ្រោងការណ៍នៃការសិក្សា (៦)

**ជំពូកទី ២ រំលឹកបញ្ហាប្រឈមនៃការគ្រប់គ្រង និងអនុវត្តថវិកា** (៨)

២.១ និយមន័យពាក្យគន្លឹះ (៨)

២.២ នីតិវិធីនៃការគ្រប់គ្រង និងការអនុវត្តថវិកាកម្មវិធី (៨)

២.២.១ អង្គភាពគ្រប់គ្រងកម្មវិធី និងអនុកម្មវិធី (៨)

២.២.១.១ អង្គភាពគ្រប់គ្រងកម្មវិធី (៩)

២.២.១.២ អង្គភាពគ្រប់គ្រងអនុកម្មវិធី (៩)

២.២.២ មុខងារ និងភារកិច្ចរបស់ប្រធានអង្គភាពគ្រប់គ្រង និងអនុវត្តសកម្មភាព (១១)

២.២.២.១ មន្ទីរអប់រំ យុវជន និងកីឡា (១១)

២.២.២.២ ការិយាល័យអប់រំ យុវជន និងកីឡា (១២)

២.២.២.៣ សាលារៀន (១២)

២.២.៣ នីតិវិធី និងយន្តការចំណាយថវិការជ្ជទេយ្យបុរេប្រទាន (១២)

២.២.៤ ដំណើរប្រព្រឹត្តទៅនៃការរៀបចំបោះផ្សាយអាណត្តិទូទាត់ (១៣)

២.២.៤.១ សាលារៀន (១៣)
២.២.៤.២ ការិយាល័យអប់រំ យុវជន និងកីឡា (១៣)
២.២.៤.៣ មន្ទីរអប់រំ យុវជន និងកីឡា (១៣)
២.២.៥ លំហូរថវិកា (១៣)
២.២.៥.១ លំហូរចំណូលថវិកា (១៤)
២.២.៥.២ លំហូរចំណាយថវិកា (១៥)
២.២.៦ គោលការណ៍ចំណាយសម្រាប់បឋមសិក្សា (១៥)
២.២.៧ ការកសាងផែនការអភិវឌ្ឍសាលារៀន (១៦)
២.៣ បញ្ហាប្រឈមនៃការគ្រប់គ្រង និងអនុវត្តថវិកាកន្លងមក (១៦)

**ជំពូកទី ៣ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ** (២០)
៣.១ ប្រភេទប្រធានបទ (២០)
៣.២ ឧបករណ៍ប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យ (២០)
៣.៣ ការជ្រើសរើសគំរូ ឬសំណាក (២០)
៣.៤ ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ (២២)
៣.៥ ការប្រមូលទិន្នន័យ (២២)
៣.៥.១ ទិន្នន័យទី១ (២២)
៣.៥.១.១ កម្រងសំណួរ (២២)
៣.៥.១.២ ការសម្ភាសន៍ (២២)
៣.៥.២ ទិន្នន័យទី២ (២៣)
៣.៦ ការវិភាគទិន្នន័យ (២៣)
៣.៧ ក្រមសីលធម៌ក្នុងការសិក្សាស្រាវជ្រាវ (២៣)

**ជំពូកទី ៤ ការពិភាក្សានិងសេចក្តីសន្និដ្ឋាន** (២៥)
៤.១ ការពិភាក្សា (២៥)
៤.២ សេចក្តីសន្និដ្ឋាន (២៨)
៤.៣ ការឆ្លុះបញ្ចាំង (២៩)
៤.៤ ដែនកំណត់និងអនុសាសន៍ (៣១)

**ឯកសារយោង** (៣៥)

**ឧបសម្ព័ន្ធ** (៣៧)

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| PAP | : | ថវិកាកម្មវិធីសកម្មភាពជាអាទិភាព |
| PB | : | ថវិកាកម្មវិធី |
| MTEF | : | ក្របខណ្ឌចំណាយរយៈពេលមធ្យម |
| MOEYS | : | ក្រសួងអប់រំ យុវជន និងកីឡា |
| MEF | : | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| PETS | : | ការធ្វើអង្កេតរបស់ក្រុមត្រួតពិនិត្យចំណាយសាធារណៈ |
| POE | : | មន្ទីរអប់រំ យុវជន និងកីឡា |
| DOE | : | ការិយាល័យអប់រំ យុវជន និងកីឡា |
| PT | : | រតនាគារខេត្ត |

# ជំពូកទី ១
# សេចក្តីផ្តើម

## ១.១ សារធាតុ

បន្ទាប់ពីសង្គ្រាមដ៏រ៉ាំរ៉ៃជាងពីរទសវត្សរ៍កន្លងមក ហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យនៅក្នុងប្រទេសត្រូវបានបំផ្លាញស្ទើរតែទាំងស្រុង។ ក្នុងការស្តារប្រទេសឡើងវិញ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំយ៉ាងខ្លាំងក្នុងការអភិវឌ្ឍន៍ជាបណ្តើរៗលើគ្រប់វិស័យ គឺនៅក្រោយការបោះឆ្នោតជាសកល និងជាប្រវត្តិសាស្ត្រនៅឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានបន្តបោះជំហានទៅមុខយ៉ាងលឿនលើការធ្វើកំណែទម្រង់ឆ្ពោះទៅកាន់សេដ្ឋកិច្ចទីផ្សារសេរី(រាជរដ្ឋាភិបាល ២០០៤)។ ជាមួយគ្នានេះដែរ កម្មវិធីកំណែទម្រង់ជាច្រើនក៏ត្រូវបានដាក់ឲ្យអនុវត្តដើម្បីសម្រេចឲ្យបាននូវគោលនយោបាយដែលជាអាទិភាពក្នុងការអភិវឌ្ឍន៍ជាតិ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ជាពិសេសកំណែទម្រង់លើវិស័យសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ដែលជាវិស័យមួយដ៏សំខាន់បំផុតក្នុងការទ្រទ្រង់លើគ្រប់វិស័យ។

គោលបំណងនៃការធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអនុវត្តកម្មវិធី គឺសំដៅដាក់ចេញកម្រិតស្តង់ដារនៃការគ្រប់គ្រង និងគណនេយ្យភាពឲ្យកាន់តែខ្ពស់ថែមទៀត ក្នុងការកៀងគរវាល់ប្រភពធនធានចរន្ត និងធនធានមូលធនរបស់រាជរដ្ឋាភិបាល ព្រមទាំងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនូវបណ្តាធនធានទាំងនេះ ក្នុងកិច្ចប្រតិបត្តិការអនុវត្តយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រនិងកម្មវិធីជាអាទិភាពផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល(រាជរដ្ឋាភិបាល ២០០៤)។ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបើកការដ្ឋានកំណែទម្រង់បួនមុខព្រួយសំខាន់ៗដែលផ្តោតលើ: (១)-កំណែទម្រង់រដ្ឋបាល និងគោលនយោបាយគយ (២)-កំណែទម្រង់រដ្ឋបាលនិងគោលនយោបាយពន្ធដារ (៣)-កំណែទម្រង់ប្រតិបត្តិការរតនាគារជាតិ និង (៤)-កំណែទម្រង់ការរៀបចំ និងប្រតិបត្តិការថវិកា(រាជរដ្ឋាភិបាល ២០០៤ )។

កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ត្រូវបានដាក់ឲ្យអនុវត្តជាបួនដំណាក់កាល៖ ដំណាក់កាលទី១(២០០៥-២០០៧)៖ ភាពជឿទុកចិត្តលើថវិកា, ទី២(២០០៨-២០១០)៖ គណនេយ្យភាពហិរញ្ញវត្ថុ, ទី៣(២០១១-២០១៣)៖ ការផ្សារភ្ជាប់ថវិកា និងគោលនយោបាយ, និងទី៤(២០១៤-២០១៥)៖ គណនេយ្យភាពចំពោះសមិទ្ធកម្ម(រាជរដ្ឋាភិបាល ២០០៤)។ កម្មវិធីនេះត្រូវបានអនុម័តយល់ព្រមដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៤ និងប្រកាសឲ្យអនុវត្តជាផ្លូវការនៅថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៤(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៩)។

ស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(២០០៥-២០១៥) និងដើម្បី

សម្រេចបាននូវទិសដៅជាយុទ្ធសាស្ត្ររាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវវិធានការណ៍កំណែទម្រង់ស៊ីជំរៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតជាសំខាន់លើការកៀងគរចំណូល ការធ្វើវិចារណៈកម្ម និងការពង្រឹងការគ្រប់គ្រងចំណាយថវិកា ការពង្រឹងអភិបាលកិច្ចល្អ និងការប្រយុទ្ធប្រឆាំងនឹងអំពើរពុករលួយ ដោយផ្តោតជាសំខាន់លើគោល-ការណ៍បង្វែរអាទិភាពចំណាយពីវិស័យយោធា-សន្តិសុខ ដើម្បីបង្កើនចំណាយលើផ្នែកសង្គម-សេដ្ឋកិច្ច។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ក្រសួងអាទិភាពចំនួន៧ ដើម្បីដាក់ឲ្យអនុវត្តសាកល្បងនូវថវិកាកម្មវិធីសកម្មភាពជាអាទិភាព(PAP) និងថវិកាកម្មវិធី(PB) ទាំងនៅថ្នាក់រដ្ឋបាលកណ្តាល និងថ្នាក់រាជធានី-ខេត្តក្រោមឱវាទក្រសួងសាមី ដែលក្នុងនោះរួមមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសុខាភិបាល, ក្រសួងយុត្តិធម៌, ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា។ បន្ទាប់មក នៅឆ្នាំ២០០៨ ការសាកល្បងនេះត្រូវបានពង្រីកវិសាលភាពដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយនៅជំហានបន្តបន្ទាប់នឹងពង្រីកវិសាលភាពទៅដល់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តផ្សេងៗទៀត ដើម្បីឈានទៅអនុវត្តឲ្យបានពេញលេញនៅដំណាក់កាលទី៣ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(MEF,2009)។

ការកំណត់វិស័យអប់រំជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពទាំង៨នេះ ដោយហេតុថា វិស័យអប់រំគឺជាវិស័យមួយយ៉ាងសំខាន់ក្នុងការបណ្តុះធនធានមនុស្ស ដែលកន្លងមក ធនធានទាំងនេះមួយចំនួនធំត្រូវបានបំផ្លាញ និងស្ទើរតែបាត់បង់ទាំងស្រុងក្នុងរបបដ៏ខ្មៅងងឹត។ វិស័យអប់រំត្រូវបានចាប់ដំណើរការជាបណ្តើរៗបន្ទាប់ពីថ្ងៃរំដោះ៧មករា១៩៧៩ ក្រោមរូបភាពខ្វះមុខខ្វះក្រោយយ៉ាងខ្លាំង ទាំងធនធានមនុស្ស និងធនធានសម្ភារៈ(MoEYS, 2007)។ សកម្មភាពបណ្តុះពុទ្ធិនាសម័យនោះគឺត្រូវបានអនុវត្តតាមយុទ្ធសាស្ត្រអ្នកចេះច្រើន បង្រៀនអ្នកចេះតិច។ ជាពិសេសជាងនេះ វប្បធម៌-អរិយធម៌ខ្មែរទាំងមូលបានរត់ទៅជ្រកកោននៅតាមទីវត្តអារ៉ាម ដែលព្រះសង្ឃគឺជាសកម្មជនក្នុងការបណ្តុះពុទ្ធិ និងផ្ទេរពុទ្ធិទាំងនោះទៅឲ្យអនក្ខរជនដែលទទួលរងផលប៉ះពាល់ពីសង្គ្រាមយ៉ាងអណោចអធម។ ប្រឈមមុខនឹងបញ្ហានេះ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ទិសដៅលើកកម្ពស់គុណភាពអប់រំដោយផ្តើមចេញពីការបណ្តុះបណ្តាលគ្រូបង្រៀនតាំងពីមតេយ្យសិក្សា រហូតដល់ថ្នាក់ឧត្តមសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅក្នុងសង្គម។ បន្ទាប់ពីមានលំនឹងភាពបណ្តើរៗផ្នែកធនធានមនុស្ស ក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្តើមកែលម្អកម្មវិធីសិក្សា សៀវភៅសិក្សា និងប្រព័ន្ធអប់រំជាបន្តបន្ទាប់ដើម្បីឈានទៅរកការអប់រំមួយដែលមានលក្ខណៈសកល និងមានស្តង់ដារនៅក្នុងតំបន់ក៏ដូចជាក្រៅតំបន់ ដែលក្នុងនោះរួមមាន៖ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៦ អនុវត្តប្រព័ន្ធអប់រំ១០ឆ្នាំ(៤+៣+៣) ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៩៦ អនុវត្តប្រព័ន្ធអប់រំ១១ឆ្នាំ(៥+៣+៣) និងពីឆ្នាំ១៩៩៦ រហូតដល់បច្ចុប្បន្នអនុវត្តប្រព័ន្ធអប់រំ១២ឆ្នាំ(៦+៣+៣) (MoEYS, 2007)។

ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងអាទិភាពមួយក្នុងចំណោមក្រសួងអាទិភាពទាំងប្រាំបី ដែលត្រូវបានដាក់ឲ្យអនុវត្តសាកល្បងនូវថវិកាPAP និងថវិកាPB។ ក្នុងដំណាក់កាលទី១ ជំហាន១នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានអនុវត្តសាកល្បងនូវថវិកាPAPចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៦ ដោយផ្តោតសំខាន់ទៅលើការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំមូលដ្ឋាន(ពីថ្នាក់ទី១ ដល់ទី៦)។ ការដាក់ឲ្យអនុវត្តសាកល្បងថវិកាPAPនេះ គឺក្នុងគោលបំណងកាត់បន្ថយបន្ទុកចំណាយក្រៅផ្លូវការរបស់មាតាបិតាសិស្ស លើកកម្ពស់គុណភាពអប់រំបឋមសិក្សាតាមរយៈការបង្កើនថវិកាសម្រាប់ដំណើរការសាលារៀន និងការបណ្តុះបណ្តាលគ្រូនៅតាមមូលដ្ឋានសាលារៀន លើកកម្ពស់ប្រសិទ្ធភាព និងកាត់បន្ថយអត្រាត្រួតថ្នាក់នៅបឋមសិក្សា តាមរយៈការបំប៉នសិស្សខ្សោយថ្នាក់ទី១ និងទី២ (នាយកដ្ឋានបឋមសិក្សា, ២០០៩)។

ការអនុវត្តសាកល្បងនេះ ក្រសួងអប់រំបានចាប់ផ្តើមអនុវត្តជាដំបូងនៅក្នុងខេត្តចំនួន ១០ (ខេត្តកំពង់ឆ្នាំង, កំពង់ស្ពឺ, កំពត, កណ្តាល, កែប, ក្រចេះ, កោះកុង, ព្រៃវែង, រតនគីរី និងស្វាយរៀង) ដែលមានកម្រិតក្រីក្រខ្ពស់ អត្រាចុះឈ្មោះចូលរៀននិងវត្តមានទាប និងអត្រាត្រួតថ្នាក់ខ្ពស់។ នៅឆ្នាំ២០០១ ការអនុវត្តថវិកាPAPត្រូវបានពង្រីកទូទាំងប្រទេសក្នុង២៤រាជធានី-ខេត្ត។ នៅឆ្នាំ២០០២ ថវិកានេះត្រូវបានពង្រីករហូតដល់មធ្យមសិក្សាទុតិយភូមិ ហើយចាប់ពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០០៦ ថវិកាPAPបន្តអនុវត្តនៅ២៤រាជធានី-ខេត្ត ដោយបានបញ្ចូលកម្មវិធីអប់រំកុមារតូច និងកម្មវិធីអាហារូបករណ៍ផងដែរ(នាយកដ្ឋានបឋមសិក្សា ២០០៩)។

ចាប់ពីឆ្នាំ ២០០៧ រហូតដល់បច្ចុប្បន្ន តាមរយៈកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ជំហាន២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្តូរយុទ្ធវិធីនៃការអនុវត្តថវិកាកម្មវិធីសកម្មភាពជាអាទិភាព(PAP) មកជាការអនុវត្តថវិកាកម្មវិធី(PB) តាមរយៈការកែលម្អកម្មវិធីសកម្មភាពជាអាទិភាព និងការសាកល្បងអនុវត្តក្របខណ្ឌចំណាយរយៈពេលមធ្យម(MTEF)

"បម្លាស់ប្តូរនៃការអនុវត្តថវិកាថ្មី(PB)នេះ មានលក្ខណៈខុសពីការអនុវត្តថវិកាចាស់(PAP) ដែលទាមទារឲ្យអ្នកអនុវត្តថវិកាទាំងអស់នៅគ្រប់កម្រិត តាំងពីថ្នាក់កណ្តាលរហូតដល់សាលារៀន មានគណនេយ្យភាពល្អជាងមុន តម្លាភាព និងបង្កើននូវទំនុកចិត្តដល់រាជរដ្ឋាភិបាល ម្ចាស់ជំនួយ ព្រមទាំងដៃគូរអភិវឌ្ឍន៍វិស័យអប់រំទាំងអស់ ហើយក៏ទាមទារផងដែរឲ្យមានការយល់ដឹងឲ្យបានច្បាស់ពីនីតិវិធីនៃការគ្រប់គ្រង និងប្រើប្រាស់ថវិកាថ្មីនេះ"(សុន្ទរកថារបស់ឯកឧត្តម ជា អៀង អនុរដ្ឋលេខាធិការក្រសួង អប់រំ យុវជន និងកីឡា ២០០៩)។

ថវិកាកម្មវិធីជួយពង្រឹងដល់ការផ្សារភ្ជាប់រវាងថវិកា និងគោលនយោបាយតាមវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រោះថាថវិកាជាឧបករណ៍គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរួមមានគោលនយោបាយចំណូល និងគោលនយោបាយចំណាយ។ ការផ្សារភ្ជាប់នេះ នឹងជំរុញការយកចិត្តទុកដាក់ទៅលើការបញ្ជាក់ពីមូល-

ហេតុនៃតម្រូវការចំណាយ និងគណនេយ្យភាពចំពោះលទ្ធផលដែលត្រូវសម្រេចបាន។(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១១ ទំព័រ ៥)

ផ្ទុយទៅវិញ ការរៀបចំថវិកាតាមមាតិកា គឺជាការធ្វើថវិកាតាមប្រភេទ ជំពូក គណនី និងអនុគណនី ដែលមិនអាចឲ្យយើងសម្រេចបំណងខាងលើនេះបានទេ ពីព្រោះការរៀបចំថវិកាតាមមាតិកាអនុញ្ញាតឲ្យយើងកត់ត្រាបានតែមុខសញ្ញាចំណាយតាមបែបសេដ្ឋកិច្ចដែលបម្រើតែគោលដៅរបាយការណ៍គណនេយ្យប៉ុណ្ណោះ។ ជារួម ថវិកាតាមមាតិកាមិនបានជួយផ្សារភ្ជាប់ទំហំចំណាយលើធាតុចូលដែលបានផ្តល់ទៅនឹងលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយដែលក្រសួងរំពឹងទុកទេ។ ជាលទ្ធផល ការអនុវត្តថវិកាតាមមាតិកា បង្កើតជាផ្នត់គំនិតមួយឲ្យក្រសួងទាមទារកំណើនថវិកាប្រចាំឆ្នាំ ដោយផ្អែកតែទៅលើថវិកាឆ្នាំកន្លងមក ដោយមិនបានយកចិត្តទុកដាក់ដល់លទ្ធផលរំពឹងទុកឡើយ(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១១ ទំព័រ៥)។

ម្យ៉ាងទៀត ការអនុវត្តថវិកាកម្មវិធីទាមទារឲ្យអ្នកអនុវត្តធ្វើការចំណាយរួចហើយ ត្រូវរៀបចំឯកសារមកទូទាត់ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី-ខេត្តតាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តសាមី ដើម្បីបានបើកសាច់ប្រាក់យកទៅចំណាយបន្តទៀត ប្រសិនបើពុំមានឯកសារយកទៅទូទាត់ទេ គឺគ្មានថវិកាយកទៅចំណាយអនុវត្តសកម្មភាពបន្តទៀតឡើយ។ រីឯការអនុវត្តថវិកាកម្មវិធីសកម្មភាពជាអាទិភាពវិញ គឺមិនបានទាមទារឲ្យអ្នកអនុវត្តៗការចំណាយរួចហើយ ត្រូវរៀបចំឯកសារទៅទូទាត់ទេ គឺចំណាយៗហើយត្រូវរៀបចំឯកសារចំណាយទាំងនោះតម្កល់ទុកនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តរង់ចាំការធ្វើសវនកម្ម បន្ទាប់មកត្រូវទៅបើកសាច់ប្រាក់បន្តទៀត ដើម្បីយកទៅអនុវត្តសកម្មភាពចំណាយបន្ត។ ជាងនេះទៅទៀត ការអនុវត្តថវិកាកម្មវិធី ត្រូវផ្អែកទៅតាមមុខសញ្ញាចំណាយនៃមាតិកាថវិកា ដែលកំណត់ទៅតាមជំពូក គណនី និងអនុគណនី ហើយមុខសញ្ញាចំណាយនេះត្រូវបានចែកចេញជា៥ជំពូករួមមាន៖ ជំពូក៦០(ការទិញ) ៦១(សេវាខាងក្រៅ) ៦២(សេវាខាងក្រៅផ្សេងៗ) ៦៤(បន្ទុកបុគ្គលិក) និង៦៥ (ឧបត្ថម្ភកធននិងជំនួយសង្គម) ដែលផ្ទុយពីការចំណាយថវិកាPAPដែលមានតែមួយជំពូកចំណាយប៉ុណ្ណោះ គឺជំពូក១៣ដែលការចំណាយ ត្រូវផ្អែកលើសកម្មភាពរបស់នាយកដ្ឋានជំនាញនីមួយៗដែលផ្តល់ឲ្យរាជធានី-ខេត្តធ្វើការចំណាយ។

តើលក្ខណៈខុសគ្នាទាំងនេះ គឺជាបញ្ហាប្រឈមដែលរាំងស្ទះដល់ដំណើរការនៃការអនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡាដែរ ឬទេ?

## ១.២ ការកំណត់បញ្ហា

ការអនុវត្តថវិកាកម្មវិធីពីមួយឆ្នាំទៅមួយឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡាមិនទាន់ឆ្លើយតបតាមចំណុចដៅ និងសូចនាករដែលកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងអប់រំ យុវជន និងកីឡាបានកំណត់នៅឡើយទេ(៩៥%)។ នាឆ្នាំដំបូងនៃការអនុវត្តថវិកាគឺមានតែមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញតែមួយគត់ក្នុងចំណោមមន្ទីរអប់រំ យុវជន និង

កីឡារាជធានី-ខេត្តទាំង២៤ ដែលបានធ្វើការទូទាត់លើសពី ៩០% នៃថវិកាសរុបដែលមន្ទីរបានទទួល(នាយកដ្ឋានហិរញ្ញវត្ថុ ២០០៨)។ ម្យ៉ាងវិញទៀត ពីមួយឆ្នាំទៅមួយឆ្នាំ ក្រសួងអប់រំ យុវជន និងកីឡាពុំដែលចំណាយថវិកាកម្មវិធីអស់ឡើយ។ នៅឆ្នាំដំបូងនៃការអនុវត្តថវិកាកម្មវិធី(២០០៧) ក្រសួងនៅសល់ ៣៧.៩% (មន្ទីរអយក.រាជធានី-ខេត្ត ៣៨.៨% អង្គភាពថ្នាក់ជាតិ ៣៩.៥%)។ ឆ្នាំ២០០៨នៅសល់ ១៩.៥% (មន្ទីរអយក.រាជធានី-ខេត្ត ២០.៧% អង្គភាពថ្នាក់ជាតិ ១០.៩%)។ ឆ្នាំ២០០៩នៅសល់ ១០.១% (មន្ទីរអយក.រាជធានី-ខេត្ត ១១.១% អង្គភាពថ្នាក់ជាតិ ៥.០%)។ ឆ្នាំ២០១០នៅសល់ ៨.៧% (មន្ទីរអយក.រាជធានី-ខេត្ត ៦.៨% អង្គភាពថ្នាក់ជាតិ ១៥.១%) និងឆ្នាំ២០១១នៅសល់ ៨.៣%(មន្ទីរអយក.រាជធានី-ខេត្ត ៧.៦% អង្គភាពថ្នាក់ជាតិ ១០.២%)(នាយកដ្ឋានហិរញ្ញវត្ថុ ២០០៧, ២០០៨, ២០០៩, ២០១០, ២០១១)។ ជាងនេះទៅទៀត មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តតែងតែរាយការណ៍មកក្រសួងអប់រំ យុវជន និងកីឡាអំពីការលំបាក និងបញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ដំណើរការនៃការអនុវត្តថវិកាកម្មវិធីនៅមន្ទីរសាមី ហើយដែលបញ្ហាទាំងនេះភាគច្រើនផ្តើមចេញពីការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅតាមបណ្តាសាលារៀន ពីព្រោះថា ថវិកាកម្មវិធីមួយផ្នែកធំត្រូវបានចំណាយសំដៅជួយគាំទ្រសកម្មភាពសម្រាប់ដំណើរការសាលារៀន។

## ១.៣ គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងសំខាន់នៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីបានដឹងថាតើថវិកាកម្មវិធីត្រូវបានចំណាយលើសកម្មភាពអ្វីខ្លះសម្រាប់ឧបត្ថម្ភដំណើរការសាលារៀន ព្រមទាំងរបៀបនៃការគ្រោង និងបែងចែកថវិកា។ ជាងនេះទៅទៀត ដើម្បីស្វែងយល់ពីការលំបាកដែលជាបញ្ហាប្រឈមពិតប្រាកដដល់ការងារគ្រប់គ្រង និងការអនុវត្តថវិកាកម្មវិធីជាក់ស្តែងនៅសាលាបឋមសិក្សាតាមរយៈការគ្រោងថវិកា ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ការស្នើសុំថវិកា ការចំណាយថវិកា ព្រមទាំងការទូទាត់ថវិកា និងជាពិសេសដើម្បីស្វែងយល់អំពីមូលហេតុនៃការចំណាយថវិកាមិនអស់។ ជាមួយគ្នានេះដែរ ក៏ដើម្បីស្វែងយល់អំពីដំណោះស្រាយមួយចំនួនដែលសាលារៀន ក៏ដូចជាអង្គភាពពាក់ព័ន្ធរួមគ្នាដោះស្រាយចំពោះបញ្ហាដែលកើតមានឡើងចំពោះមុខ ដូចជាកន្លងមក មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តមួយចំនួនតែងតែបានលើកឡើងអំពីបញ្ហាទឹក-ភ្លើង ពីព្រោះសាលាដែលពុំត្រូវចំណាយទឹក-ភ្លើង បែរជាមានថវិកាសម្រាប់ចំណាយទៅលើមុខចំណាយនេះទៅវិញ។ ម្យ៉ាងវិញទៀត ការសិក្សានេះក៏ដើម្បីស្វែងយល់អំពីតម្លាភាពក្នុងការងារគ្រប់គ្រង និង អនុវត្តថវិកានៅសាលារៀនផងដែរ តាមរយៈការចូលរួមរបស់សហគមន៍។

## ១.៤ សំណួរសម្រាប់ការសិក្សាស្រាវជ្រាវ

សំណួរពីរត្រូវបានប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវនេះ ៖

១-តើកត្តាអ្វីខ្លះដែលជាបញ្ហាប្រឈមពិតប្រាកដក្នុងការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធី ដែលសាលាបាន និងកំពុងជួបប្រទះ?

២-តើសាលារៀន ក៏ដូចជាអង្គភាពពាក់ព័ន្ធ មានដំណោះស្រាយបែបណាក្នុងការដោះស្រាយនូវបញ្ហាប្រឈមដែលកើតមានឡើងចំពោះមុខ?

## ១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សានេះនឹងស្វែងរកឲ្យឃើញនូវបញ្ហាប្រឈមពិតៗដែលសាលាបាន និងកំពុងជួបប្រទះ ព្រមទាំងដំណោះស្រាយមួយដ៏ប្រសើរ និងសមស្របសម្រាប់ឲ្យការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅសាលារៀនប្រកបដោយ តម្លាភាព គណនេយ្យភាព និងទទួលបានប្រសិទ្ធភាពខ្ពស់។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ មិនត្រឹមតែជាអត្ថប្រយោជន៍សម្រាប់ការងារគ្រប់គ្រង និងអនុវត្តថវិកានៅកម្រិតសាលារៀនប៉ុណ្ណោះទេ ថែមទាំងជាសារៈប្រយោជន៍ដល់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅគ្រប់លំដាប់ថ្នាក់ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា អង្គភាពពាក់ព័ន្ធ និងដៃគូពាក់ព័ន្ធនានា បានយល់ និងជ្រាបកាន់តែច្បាស់អំពីអ្វីដែលជាបញ្ហាប្រឈមជាក់ស្តែងដែលសាលាបាន និងកំពុងជួបប្រទះ ព្រមទាំងផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងចំពោះបញ្ហាប្រឈមទាំងឡាយដែលបាននិងកំពុង ឬក៏រៀបនឹងកើតមានឡើងដើម្បីបានរកដំណោះស្រាយដ៏សមស្របសម្រួលការងារឲ្យបានទាន់ពេលវេលាព្រមទាំងជួយជំរុញការងារអនុវត្តថវិកានៅកម្រិតសាលារៀនឲ្យទទួលបានលទ្ធផលល្អ ស្របតាមទិសដៅដែលក្រសួងបានកំណត់។ម្យ៉ាងវិញទៀត ការសិក្សានេះនឹងជាជំនួយ ផ្តល់ជាបទពិសោធន៍ និងជាប្រយោជន៍ ដល់សាលារៀនមួយចំនួនទៀតដែលការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីពុំទាន់ឆ្លើយតបតាមផែនការដែលបានកំណត់ និងតាមតម្រូវការជាក់ស្តែង។ ពិសេសជាងនេះទៅទៀត ការសិក្សានេះ នឹងអាចជាវិធីសាស្ត្រមួយដ៏ល្អក្នុងការទប់ស្កាត់ឲ្យបានទាន់ពេលវេលានូវរាល់បញ្ហាប្រឈមដែលនឹងកើតមានឡើងចំពោះសាលារៀនមួយចំនួនដែលមិនទាន់មានបញ្ហា ឬក៏រៀបនឹងមាន។ បន្ថែមពីលើនេះ ការសិក្សានេះគឺដើម្បីឲ្យបានដឹងប្រាកដថាតើក្រសួងអប់រំ យុវជន និងកីឡា ជាពិសេស សាលារៀន និងអង្គភាពពាក់ព័ន្ធមានដំណោះស្រាយបែបណា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមដែលសាលាបាន និងកំពុងជួបប្រទះនៅចំពោះមុខ។ម្យ៉ាងវិញទៀត ការសិក្សានេះក៏ដើម្បីរួមចំណែកផ្តល់ជាអនុសាសន៍ឲ្យភាគីពាក់ព័ន្ធទាំងអស់ ពិចារណាក្នុងការរិះរកដំណោះស្រាយ និងកែលម្អនូវបញ្ហាទាំងនោះឲ្យបានទាន់ពេលវេលា ដើម្បីឲ្យការងារគ្រប់គ្រងនិងការអនុវត្តថវិកាកម្មវិធីនៅសាលាបឋមសិក្សាទទួលបានប្រសិទ្ធភាពកាន់តែប្រសើរឡើង ជាពិសេស គឺការទូទាត់ការចំណាយបានទាន់ពេលវេលា និងសម្រេចលទ្ធផលបានតាមទិសដៅដែលកំណត់។

## ១.៦ គ្រោងការណ៍នៃការសិក្សា

របាយការណ៍ស្រាវជ្រាវនេះ ត្រូវបានបែងចែកជាបួនជំពូក។ ជំពូកទី១ គឺសេចក្តីផ្តើម ដែលបរិយាយអំពីសារបាននៃការកកើតថវិកាកម្មវិធី ការកំណត់បញ្ហា គោលបំណង សំណួរស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ ព្រមទាំងគ្រោងការណ៍នៃការសិក្សា។ ជំពូកទី២ លើកឡើងនូវទ្រឹស្តីទូទៅដែលទាក់ទងទៅនឹងនីតិវិធី និងគោលការណ៍ នៃការងារគ្រប់គ្រងនិងអនុវត្តថវិកាកម្មវិធី ព្រមទាំងលើកឡើងនូវបញ្ហាប្រឈមនានាដែលកើតមានឡើងនៅកម្រិតសាលារៀនកន្លងមក។ ជំពូកទី៣ លើកឡើងអំពីគម្រោងនៃការស្រាវជ្រាវ ឧបករណ៍ប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យ ការកំណត់ក្រុមដែលត្រូវធ្វើការសិក្សា នីតិវិធីនៃការប្រមូលទិន្នន័យ វិធីសាស្ត្រនៃការវិភាគ និងក្រមសីលធម៌ក្នុងការប្រមូលទិន្នន័យ។ ជំពូកទី៤ គឺជាជំពូកចុងក្រោយ ដែលជាការពិភាក្សា សេចក្តីសន្និដ្ឋាន គំនិតឆ្លុះបញ្ចាំង និងការផ្តល់នូវចំណុចផ្សេងៗទៀតដែលជាការស្នើសុំទៅលើលទ្ធផលនៃការវិភាគខាងលើមួយចំនួន ដើម្បីឲ្យការសិក្សាក្រោយៗទៀតបានកែលម្អនូវចំណុចខ្វះខាតដែលបានសង្កេតឃើញ នោះនឹងធ្វើឲ្យការសិក្សាស្រាវជ្រាវនេះកាន់តែមានន័យ និងទទួលបាននូវប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

# ជំពូកទី ២
# ការរំលឹកបញ្ហាប្រឈមនៃការគ្រប់គ្រង និងអនុវត្តថវិកា

## ២.១ និយមន័យពាក្យគន្លឹះ

យោងតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(២០១១) ថវិកាកម្មវិធី គឺជាការរៀបចំថវិកាដោយផ្អែកលើកម្មវិធីច្បាស់លាស់ ដើម្បីឈានទៅសម្រេចគោលបំណង គោលនយោបាយរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ស្របតាមគោលនយោបាយដែលមានចែងនៅក្នុងវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ថវិកាកម្មវិធីត្រូវមានសូចនាករ សមិទ្ធកម្ម សម្រាប់ជាយន្តការតាមដានដើម្បីវាស់វែង និងធ្វើរបាយការណ៍លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយទៅតាមអនុកម្មវិធី និងកម្មវិធីនីមួយៗ។ ថវិកាកម្មវិធីត្រូវកំណត់ឲ្យបានច្បាស់នូវថ្លៃធាតុចូល ដែលរួមមានចំណាយចរន្ត និងចំណាយមូលធនចាំបាច់ សម្រាប់ការអនុវត្តចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១១ ទំព័រ៥)។

ថវិកាកម្មវិធី គឺជាប្រភេទថវិការជួទេយ្យបុរេប្រទាន(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៧) ដែលត្រូវបានដាក់ឲ្យអនុវត្តសាកល្បងនៅក្រសួងអប់រំ យុវជន និងកីឡាចាប់ពីឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ននេះ។ ការដាក់ឲ្យអនុវត្តសាកល្បងនូវប្រភេទថវិកានេះនៅក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការអប់រំនៅបឋមសិក្សា កម្មវិធី "ពង្រឹងគុណភាពនិងប្រសិទ្ធភាពអប់រំនៅបឋមសិក្សា" គឺក្នុងគោលបំណងបង្កើនការចូលរៀនរបស់សិស្សពីថ្នាក់ទី១ ដល់ទី៦ កាត់បន្ថយអត្រាត្រួតថ្នាក់ និងការបោះបង់ការសិក្សាតាមរយៈការកាត់បន្ថយបន្ទុកចំណាយក្រៅផ្លូវការរបស់មាតាបិតាសិស្ស និងការបង់វិភាគទានគ្រប់រូបភាព។ ជាងនេះទៅទៀត ដើម្បីបង្កើនការឡើងថ្នាក់ បង្កើនអត្រាឆ្លងភូមិសិក្សា និងអត្រាបញ្ចប់ការសិក្សា ព្រមទាំងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលារៀន បង្កើនការចូលរួមរបស់សហគមន៍ និងតម្លាភាពគ្រប់គ្រង(នាយកដ្ឋានបឋមសិក្សា ២០១១)។

ដើម្បីបានយល់កាន់តែច្បាស់អំពីការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀន ជាដំបូងត្រូវស្វែងយល់អំពីនីតិវិធី ឬគោលការណ៍ នៃការគ្រប់គ្រងនិងអនុវត្តថវិកាកម្មវិធីមួយចំនួន ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជានាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ណែនាំឲ្យអង្គភាពក្រោមឱវាទអនុវត្ត ជាពិសេសអង្គភាពថ្នាក់ក្រោមជាតិ។ ការលើកឡើងនូវនីតិវិធី ឬគោលការណ៍ណែនាំនេះ គឺក្នុងគោលបំណងដើម្បីងាយស្រួលក្នុងការប្រៀបធៀបជាមួយបញ្ហាប្រឈមដែលកើតមានឡើងនៅកម្រិតសាលារៀន។

## ២.២ នីតិវិធីក្នុងការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធី

### ២.២.១ អង្គភាពគ្រប់គ្រងកម្មវិធី និងអនុកម្មវិធី

ការអនុវត្តថវិកាកម្មវិធីត្រូវបានចែកចេញជាកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព។ ដោយឡែក នៅក្រសួងអប់រំ យុវជន និងកីឡា អង្គភាពថ្នាក់ជាតិដែលត្រូវអនុវត្តថវិកាកម្មវិធីចាប់តាំងពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១២នេះ មានចំនួន ៣៦អង្គភាព ដែលអង្គភាពទាំងនោះត្រូវបានបែងចែកឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានកម្មវិធី និងឲ្យអនុវត្តអនុកម្មវិធីទៅតាមមុខងារ និងភារកិច្ចរបស់នាយកដ្ឋានជំនាញនីមួយៗ(នាយកដ្ឋានហិរញ្ញវត្ថុ ២០១២)។

### ២.២.១.១ អង្គភាពគ្រងគ្រងកម្មវធី

សព្វថ្ងៃនេះ កម្មវិធីដែលត្រូវអនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡាមានចំនួន ០៥កម្មវិធី ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឯកឧត្តមអគ្គនាយកទាំង០៥ រួមមាន៖ ឯកឧត្តមអគ្គនាយកអប់រំ ឯកឧត្តមអគ្គនាយកឧត្តមសិក្សា ឯកឧត្តមអគ្គនាយកកីឡា ឯកឧត្តមអគ្គនាយកយុវជន និងឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ។ ឯកឧត្តមអគ្គនាយកទាំង៥មានភារកិច្ចជាប្រធានកម្មវិធី ៖

- កម្មវិធីទី១: ការអភិវឌ្ឍន៍អប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ
- កម្មវិធីទី២: ការអភិវឌ្ឍន៍អប់រំ បណ្តុះបណ្តាល បច្ចេកទេសឧត្តមសិក្សា និងស្រាវជ្រាវវិទ្យាសាស្ត្រ
- កម្មវិធីទី៣: ការអភិវឌ្ឍន៍វិស័យអប់រំកាយ និងកីឡា
- កម្មវិធីទី៤: ការអភិវឌ្ឍន៍យុវជន
- កម្មវិធីទី៥: ការគាំទ្រ ការគ្រប់គ្រងសេវាអប់រំ និង អភិបាលកិច្ចល្អ

ចំណែកការអប់រំនៅបឋមសិក្សា គឺស្ថិតក្រោមកម្មវិធីទី១ ″ការអភិវឌ្ឍន៍អប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ″ដែលទទួលបន្ទុកគ្រប់គ្រងដោយឯកឧត្តមអគ្គនាយកអប់រំ(នាយកដ្ឋានហិរញ្ញ-វត្ថុ ២០១២)។

### ២.២.១.២ អង្គភាពគ្រប់គ្រងអនុកម្មវធី

ក្រៅពីកម្មវិធីទាំង៥ ការអនុវត្តថវិកាកម្មវិធីមានអនុកម្មវិធីចំនួន ២៩ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានជំនាញថ្នាក់ជាតិទាំង ៣៦អង្គភាព ហើយដែលអនុកម្មវិធីទាំង ២៩នេះស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានកម្មវិធីទាំង៥ ក្នុងនោះប្រធាននាយកដ្ឋានមានភារកិច្ចជាប្រធានអនុកម្មវិធី ៖

កម្មវិធីទី១៖ "ការអភិវឌ្ឍន៍អប់រំចំណេះទូទៅ និងអប់រំក្រៅប្រព័ន្ធ

១.១- ការពង្រីកការអប់រំកុមារតូច

១.២- ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា

១.៣- ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា

១.៤- ការចូលរៀនប្រកបដោយសមធម៌ និងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក

១.៥- ការពង្រីកការអប់រំក្រៅប្រព័ន្ធ

១.៦- ការពង្រឹង និងការពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា

១.៧- លើកកម្ពស់គុណភាព និងប្រសិទ្ធិភាពនៃការអនុវត្តអប់រំបំណិនជីវិត និងតម្រង់ទិសវិជ្ជាជីវៈ

កម្មវិធីទី២៖ "ការអភិវឌ្ឍន៍អប់រំ បណ្តុះបណ្តាល បច្ចេកទេសឧត្តមសិក្សា និងស្រាវជ្រាវវិទ្យាសាស្ត្រ"

២.១- ការពង្រឹងគុណភាព និងប្រសិទ្ធិភាពនៃការអប់រំនៅឧត្តមសិក្សា

២.២- ការពង្រឹងគុណភាព និងប្រសិទ្ធិភាពនៃការអប់រំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត

កម្មវិធីទី៣៖ "ការអភិវឌ្ឍន៍វិស័យអប់រំកាយ និងកីឡា"

៣.១- ការអភិវឌ្ឍន៍សមាគមន៍កីឡាមហាជន

៣.២- ការអភិវឌ្ឍន៍សមាគមន៍កីឡាសិស្ស-និសិត្ស

៣.៣- ការបណ្តុះបណ្តាល និងស្រាវជ្រាវអប់រំកាយ និងកីឡា

៣.៤- ការអភិវឌ្ឍន៍កីឡាកម្រិតខ្ពស់

កម្មវិធីទី៤៖ "ការអភិវឌ្ឍន៍យុវជន"

៤.១- ការយល់ដឹងរបស់យុវជនអំពីជម្ងឺអេដស៍ និងការពង្រឹងសកម្មភាពយុវជន

៤.២- ការពង្រឹងសមត្ថភាព និងអភិវឌ្ឍន៍មជ្ឈមណ្ឌលយុវជន

កម្មវិធីទី៥៖ "ការគាំទ្រ ការគ្រប់គ្រងសេវា អប់រំ និង អភិបាលកិច្ចល្អ"

៥.១- ការអភិវឌ្ឍន៍គោលនយោបាយ និងពង្រឹងប្រព័ន្ធផែនការអប់រំ

៥.២- ការអភិវឌ្ឍន៍ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន

៥.៣- ការអភិវឌ្ឍន៍សម្ភារ និងសៀវភៅសិក្សា

៥.៤- ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធិភាព ធនធានមនុស្ស

៥.៥- ការអភិវឌ្ឍន៍សមត្ថភាពការងារគ្រប់គ្រងផែនការហិរញ្ញវត្ថុនិងមូលដ្ឋានសម្ភារ

៥.៦- ពង្រឹងការងារសវនកម្មផ្ទៃក្នុង

៥.៧- ការពិនិត្យតាមដាន និងវាយតម្លៃការបំពេញការងារវិស័យអប់រំទាំងមូល

៥.៨- អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ

៥.៩- ការអភិវឌ្ឍន៍ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

៥.១០- ការពង្រឹងការងារនីតិកម្មសម្រាប់វិស័យអប់រំ

៥.១១- ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ

៥.១២- ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

៥.១៣- ការអភិវឌ្ឍន៍ និងប្រសិទ្ធភាពការគ្រប់គ្រងរដ្ឋបាល

៥.១៤- ការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិលើវិស័យអប់រំ

ដោយឡែកសម្រាប់ការអប់រំនៅបឋមសិក្សា គឺស្ថិតក្រោមអនុកម្មវិធីទី២ "ការពង្រឹងគុណ-ភាព និងប្រសិទ្ធិភាពនៃការអប់រំនៅបឋមសិក្សា" នៃកម្មវិធីទី១ ដែលគ្រងគ្រងដោយនាយកដ្ឋានបឋមសិក្សា(នាយកដ្ឋានហិរញ្ញវត្ថុ ២០១២)។

## ២.២.២- មុខងារ និងភារកិច្ចរបស់អង្គភាពគ្រប់គ្រង និងអនុវត្តសកម្មភាព

កម្មវិធី និងអនុកម្មវិធីត្រូវបានគ្រប់គ្រងដោយអង្គភាពថ្នាក់ជាតិ រីឯសកម្មភាពដែលត្រូវអនុវត្តចំណាយនីមួយៗត្រូវបានផ្តល់ជូនក្នុងការគ្រប់គ្រងនិងអនុវត្តចំណាយដល់ថ្នាក់ក្រោមជាតិដែលរួមមានៈ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក-ខណ្ឌ និងជាពិសេស សាលារៀន។ សកម្មភាពដែលត្រូវអនុវត្តចំណាយទាំងនេះ គឺស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានអនុកម្មវិធីនៃអង្គភាពជំនាញថ្នាក់ជាតិ។ អង្គភាពជំនាញថ្នាក់ជាតិដែលវិភាជន៍ថវិកាកម្មវិធីទៅឲ្យអង្គភាពថ្នាក់ក្រោមជាតិអនុវត្តមានចំនួនតែ ១៥ អង្គភាពប៉ុណ្ណោះ (នា.អប់រំកុមារតូច នា.បឋមសិក្សា នា.មធ្យមសិក្សាចំណេះទូទៅ នា.អប់រំក្រៅប្រព័ន្ធ នា.សុខភាពសិក្សា នា.តម្រង់ទិសវិជ្ជាជីវៈ នា.អប់រំកាយនិងកីឡា នា.យុវជន នា.គ្រប់គ្រងមជ្ឈមណ្ឌលយុវជន នា.ផែនការ នា.បណ្តុះបណ្តាលនិងវិក្រឹតការ នា.អភិវឌ្ឍកម្មវិធីសិក្សា នា.បុគ្គលិក នា.ហិរញ្ញវត្ថុ និងនា.ធានាគុណភាពអប់រំ)។ ដោយឡែក ចំពោះសកម្មភាពដែលត្រូវអនុវត្តសម្រាប់អនុកម្មវិធី "ការពង្រឹងគុណភាពនិងប្រសិទ្ធិភាពនៃការអប់រំនៅបឋមសិក្សា"ត្រូវបានចែកចេញជា៣សកម្មភាពដែលសកម្មភាពទី១៖ ថវិកាដំណើរការសាលារៀន ទី២៖ ថវិកាពង្រឹងគុណភាពរៀននិងបង្រៀន និងទី៣៖ ការពង្រឹងការពិនិត្យតាមដាន ការបំប៉នសមត្ថភាព និងការលើកទឹកចិត្ត (នាយកដ្ឋានបឋមសិក្សា ២០១២)។

**២.២.២.១** មន្ទីរអប់រំ យុវជន និងកីឡា៖ ប្រធានមន្ទីរមានភារកិច្ចជាអាណាប័កផ្ទេរសិទ្ធ និងទទួលបន្ទុកគ្រប់គ្រង និងអនុវត្តគ្រប់អនុកម្មវិធីដែលអង្គភាពថ្នាក់ជាតិបានផ្តល់ជូន។ ប្រធានមន្ទីរមានភារកិច្ចពិនិត្យតាមដាន និងទទួលខុសត្រូវក្នុងការអនុវត្តគម្រោងផែនការសកម្មភាព និងថវិការបស់អនុកម្មវិធីនីមួយៗ ចុះហត្ថលេខាលើអាណត្តិបើកប្រាក់ សាលាកបត្រ លិខិតស្នើសុំទូទាត់ថវិកានិងសក្ខីបត្រចំណាយផ្សេងៗទៀតរបស់ការិយាល័យជំនាញចំណុះមន្ទីរផ្ទាល់ ព្រមទាំងសរុបរបាយការណ៍ស្តីពីស្ថានភាពចំណាយថវិកា និងរបាយការណ៍សូចនាកររបស់អនុកម្មវិធីនីមួយៗប្រចាំត្រីមាស ឆមាស និងឆ្នាំ(ក្រសួងអប់រំ ២០០៨ ទំព័រ ១៩១)។

**២.២.២.២** ការិយាល័យអប់រំ យុវជននិងកីឡា៖ ជាអ្នកទទួលបន្ទុកគ្រប់គ្រងរួមរាល់ផែនការសកម្មភាព និងគម្រោងថវិកាដែលមន្ទីរផ្តល់ជូនដើម្បីណែនាំ និងបែងចែកថវិកាបន្តដល់សាលារៀន។ ការិយាល័យអប់រំមានភារកិច្ចពិនិត្យតាមដាន និងទទួលខុសត្រូវក្នុងការអនុវត្តគម្រោងផែនការសកម្មភាពដែលមន្ទីរផ្តល់ជូនដើម្បីណែនាំ និងផ្សព្វផ្សាយដល់សាលារៀន រៀបចំបែងចែកថវិកាដល់សាលារៀនឲ្យបានត្រឹមត្រូវតាមការណែនាំរបស់មន្ទីរអប់រំ យុវជន និងកីឡា រៀបចំរបាយការណ៍ស្តីពីស្ថានភាពចំណាយថវិកា និងរបាយការណ៍សូចនាករប្រចាំត្រីមាស ឆមាស និងឆ្នាំដើម្បីផ្តល់ជូនមន្ទីរ(ក្រសួងអប់រំ ២០០៨ ទំព័រ ១៤២)។

**២.២.២.៣** សាលារៀន៖ ជាអ្នកទទួលបន្ទុកគ្រប់គ្រងរាល់ផែនការសកម្មភាពរបស់សាលា និងការប្រើប្រាស់ថវិកាដើម្បីឲ្យមានតម្លាភាពនិងមានប្រសិទ្ធិភាពខ្ពស់ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ សាលាមានភារកិច្ចពិនិត្យតាមដាន និងទទួលខុសត្រូវក្នុងការអនុវត្តគម្រោងផែនការសកម្មភាព និងការប្រើប្រាស់ថវិកាឲ្យបានត្រឹមត្រូវ រៀបចំរបាយការណ៍ស្តីពីស្ថានភាពចំណាយថវិកា និងរបាយការណ៍សូចនាករ ប្រចាំត្រីមាស ឆមាស និងឆ្នាំ ដើម្បីផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡា។(ក្រសួងអប់រំ ២០០៨ ទំព័រ ១៤២)

### ២.២.៣- នីតិវិធី និងយន្តការចំណាយថវិការជ្ជទេយ្យបុរេប្រទាន

**២.២.៣.១** ក្រសួងអប់រំ យុវជន និងកីឡាត្រូវតែងតាំងអាណាប័កផ្ទេរសិទ្ធ និងផ្ទេរឥណទានថវិកាកម្មវិធីជូនទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ឥណទានថវិកានេះ ឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៧ ទំព័រ ៧)

**២.២.៣.២** ថវិកាសម្រាប់ដំណើរការថ្នាក់រៀន និងការចំណាយថវិកាដែលមានគោល-ការណ៍កំណត់ច្បាស់លាស់ ត្រូវអនុវត្តតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ១០០% ដោយមិនគិត១/៤ លើ៣០%នៃឥណទានដែលជ្រើសរើសមកបង្កើត(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ២០០៧ ទំព័រ ៧)។

**២.២.៣.៣** រាល់ការចំណាយថវិកាដែលពាក់ព័ន្ធទៅនឹងការទិញ ការជួសជុល ឬសេវាផ្សេងៗដែលមានទឹកប្រាក់ក្រោម ២០លានរៀល ត្រូវអនុវត្តតាមលំនាំនីតិវិធីនៃវិធីសាស្ត្រលទ្ធកម្ម "ស្ទង់តម្លៃ" (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៧ ទំព័រ ៧)។

**២.២.៣.៤** ក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំប្រកាសអន្តរក្រសួង ស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងការបង្កើតរជ្ជទេយ្យបុរេប្រទានជូនអង្គភាពជាតិ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។ ក្រោយពីមានប្រកាសអន្តរក្រសួងទាំងពីរនេះហើយ ក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំបែបបទនៃការផ្ទេរថវិកាជំហានទី១ និងការដកសាច់ប្រាក់រជ្ជទេយ្យបុរេប្រទានសម្រាប់ជុំទី១នៅរតនាគាររាជធានី-ខេត្ត ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត (ក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៧)។

**២.២.៣.៥** ក្រោយពីបានទទួលសំណើទាំងពីរនេះរួចមក រដ្ឋទេយ្យករបុរេប្រទាន ឬរដ្ឋទេយ្យកររងបុរេប្រទាននៃមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តត្រូវលើកសំណើសុំដកសាច់ប្រាក់ត្រង់ទៅរតនាគាររាជធានី-ខេត្តតែម្តង។ ក្រោយពីបានបើកប្រាក់ពីរតនាគាររាជធានី-ខេត្តរួច មន្ទីរត្រូវរៀបចំបែងចែកសាច់ប្រាក់ជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌ ដើម្បីបន្តបើកប្រាក់ជូនសាលារៀន(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៧)។

### ២.២.៤- ដំណើរប្រព្រឹត្តទៅនៃការរៀបចំបោះផ្សាយអាណត្តទូទាត់

**២.២.៤.១ សាលារៀន**

ហេរញ្ញិកសាលាត្រូវប្រមូលយកឯកសារទូទាត់ លិខិតយុត្តិការនិងសក្ខីបត្រ ដើម្បីរៀបចំបញ្ជូនទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌ(ក្រសួងអប់រំ ២០០៨)។

**២.២.៤.២ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌ**

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌត្រូវមានភារកិច្ចប្រមូលឯកសារទូទាត់ លិខិតយុត្តិការ និងសក្ខីបត្រចំណាយពីគ្រប់សាលារៀនដែលស្ថិតនៅក្រោមឱវាទ និងពីអង្គភាពសាមី រួចត្រូវពិនិត្យឯកសារទាំងអស់ឲ្យបានត្រឹមត្រូវ ហើយរៀបចំបូកសរុបរបាយការណ៍ស្តីពីការចំណាយថវិការដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធី លើរបាយការណ៍សរុបរបស់សាលារៀនទាំងអស់ដើម្បីបញ្ជូនបន្តទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត សម្រាប់ធ្វើការទូទាត់ជាមួយនឹងរតនាគាររាជធានី-ខេត្ត(ក្រសួងអប់រំ ២០០៨)។

**២.២.៤.៣ មន្ទីរអប់រំ យុវជន និងកីឡា**

ក្នុងការរៀបចំឯកសារទូទាត់ រដ្ឋទេយ្យករបុរេប្រទានរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តត្រូវមានភារកិច្ចប្រមូលយកលិខិតយុត្តិការ និងសក្ខីបត្រចំណាយពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌ និងពីការិយាល័យជំនាញចំណុះមន្ទីរ ដើម្បីរៀបចំបោះផ្សាយអាណត្តិទូទាត់ជាមួយរតនាគាររាជធានី-ខេត្ត តាមរយៈមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្តសាមី(ក្រសួងអប់រំ ២០០៨)។

រាល់សក្ខីបត្រចំណាយ និងលិខិតយុត្តិការទាំងអស់ ត្រូវចុះហត្ថលេខាដោយអាណាប័កផ្ទេរសិទ្ធិ(ប្រធានមន្ទីរ) មុនពេលបញ្ជូនអាណត្តិទូទាត់ទាំងនោះទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្តពិនិត្យ និងចុះហត្ថលេខាក្នុងនាមជាអភិបាលហិរញ្ញវត្ថុ មុននឹងបញ្ជូនទៅរតនាគាររាជធានី-ខេត្ត។

### ២.២.៥ លំហូរថវិកា




(ប្រភព: នាយកដ្ឋានហិរញ្ញវត្ថុ ២០១១)

→ សំណើសុំដកសាច់ប្រាក់៖

(១) មន្ទីរអប់រំ យុវជន និងកីឡាស្នើសុំដកសាច់ប្រាក់ទៅរតនាគារ

(២) ការិយាល័យអប់រំ យុវជន និងកីឡាស្នើសុំដកសាច់ប្រាក់ទៅមន្ទីរអយក.

(៣) សាលារៀនស្នើសុំដកសាច់ប្រាក់ទៅការិយាល័យអយក.។

→ បានទទួលសាច់ប្រាក់៖

(១) មន្ទីរអប់រំ យុវជន និងកីឡាបានទទួលសាច់ប្រាក់ពីរតនាគារ

(២) ការិយាល័យអប់រំ យុវជន និងកីឡាបានទទួលសាច់ប្រាក់ពីមន្ទីរអយក.

(៣) សាលារៀនបានទទួលសាច់ប្រាក់ពីការិយាល័យអយក.។

-→ របាយការណ៍ និងឯកសារទូទាត់៖

(១) សាលារៀនបញ្ជូនរបាយការណ៍ និងឯកសារទូទាត់ទៅការិយាល័យអយក.

(២) ការិយាល័យអយក.សរុបរបាយការណ៍ និងឯកសារទូទាត់ដែលសាលារៀនក្រោមឱវាទបានបញ្ជូនមក រួចបញ្ជូនបន្តទៅមន្ទីរអយក.

(៣)មន្ទីរអយក.រៀបចំរបាយការណ៍និងឯកសារទូទាត់ រួចបញ្ជូនទៅរតនាគាររាជធានី-ខេត្ត ក្រោយពេលដែលមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានពិនិត្យថា ត្រឹមត្រូវហើយ ។

### ២.២.៥.១ លំហូរចំណូលថវិកា




(ប្រភព: នាយកដ្ឋានហិរញ្ញវត្ថុ ២០១១)

(១) សាលារៀនធ្វើសំណើសុំដកសាច់ប្រាក់ពីការិយាល័យអយក.ក្រុង ស្រុក-ខណ្ឌ
(២) ការិយាល័យអយក.ក្រុង ស្រុក-ខណ្ឌពិនិត្យ ហើយបើកសាច់ប្រាក់ជូននាយកសាលា
(៣) នាយកសាលាបានទទួលសាច់ប្រាក់ហើយ ត្រូវប្រគល់ទៅឲ្យហេរញ្ញិកសាលារៀន
(៤) ហេរញ្ញិកសាលាបានទទួលសាច់ប្រាក់ពីនាយកហើយ រាប់សាច់ប្រាក់ឲ្យបានត្រឹមត្រូវ ទើបធ្វើការកត់ត្រាចូលក្នុងប័ណ្ណចំណូល ដោយយោងប័ណ្ណចំណាយរបស់ការិយាល័យអយក.ក្រុង ស្រុក-ខណ្ឌ
(៥) ហេរញ្ញិកសាលាត្រូវស្រង់លេខប័ណ្ណចំណូល ថ្ងៃខែឆ្នាំ អត្ថន័យនៃប័ណ្ណចំណូល និងចំនួនទឹកប្រាក់កត់ត្រាចូលក្នុងបញ្ជីបេឡា។

### ២.២.៥.២ លំហូរចំណាយថវិកា




(ប្រភព: នាយកដ្ឋានហិរញ្ញវត្ថុ ២០១១

(១) អ្នកស្នើសុំថវិកាត្រូវធ្វើលិខិតស្នើសុំថវិកាទៅនាយកសាលា ដើម្បីយកមកចំណាយទិញ ឬជួសជុលអ្វីមួយ
(២) នាយកសាលាត្រូវពិនិត្យ ហើយចារឯកភាពលើលិខិតនោះ បន្ទាប់មកបញ្ជូនទៅហេរញ្ញិកសាលា ដើម្បីបើកសាច់ប្រាក់ជូនអ្នកស្នើសុំ
(៣) ហេរញ្ញិកសាលាទទួលបានលិខិតដែលមានចំណារឯកភាពពីនាយកសាលាហើយ ត្រូវពិនិត្យ និងកត់ត្រាចូលប័ណ្ណចំណាយ រួចបើកសាច់ប្រាក់ជូនអ្នកស្នើសុំ
(៤) ហេរញ្ញិកសាលាត្រូវស្រង់លេខប័ណ្ណចំណាយ ថ្ងៃខែឆ្នាំ អត្ថន័យនៃប័ណ្ណចំណាយ និងចំនួនទឹកប្រាក់ កត់ត្រាចូលក្នុងបញ្ជីបេឡា។

### ២.២.៦ គោលការណ៍ចំណាយ សម្រាប់បឋមសិក្សា

ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកាឲ្យបានល្អ និងស្របតាមផែនការសូចនាករសម្រាប់អនុកម្មវិធីស្តីពី “ការពង្រឹងគុណភាពនិងប្រសិទ្ធភាពអប់រំនៅបឋមសិក្សា” ក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានបឋមសិក្សា ក្រសួងបានដាក់ចេញនូវគោលការណ៍ណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តសម្រាប់អនុវត្តកម្មវិធីសកម្មភាពរបស់សាលាបឋមសិក្សាដូចខាងក្រោម៖

**២.២.៦.១** ថវិកាសម្រាប់ដំណើរការសាលារៀន៖ ផ្តល់ថវិកាដល់គ្រប់សាលាបឋមសិក្សាចំនួនពី ៥០០.០០០រៀល-៧០០.០០០រៀល ក្នុងមួយសាលានិងចំនួន ៧.០០០រៀល-៨.០០០រៀល

ក្នុងសិស្សម្នាក់ ក្នុងមួយឆ្នាំសិក្សាសម្រាប់ចំណាយលើ៖ សម្ភារមូលដ្ឋាន ការជួសជុលតូច (សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច) ការកែលម្អបរិស្ថានសាលា និងថ្នាក់រៀន បំណិនជីវិត(កីឡា សិល្បៈ រោងជាង គេហវិជ្ជា និងកសិកម្ម) ចំណាយសម្រាប់ទឹកស្អាត និងអនាម័យ ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក ការរៀបចំឯកសារធ្វើតេស្តចុងឆ្នាំសិក្សាសម្រាប់ថ្នាក់ទី៣ និងទី៦ និងចំណាយផ្សេងៗ(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៧ ទំព័រ៣ )។

**២.២.៦.២** ថវិកាសម្រាប់ពង្រឹងគុណភាពរៀន និងបង្រៀន៖ ផ្តល់ប្រាក់ឧបត្ថម្ភដល់ការប្រជុំនៅតាមកម្រងសាលារៀន(ដើមឆ្នាំ កណ្តាលឆ្នាំ និងចុងឆ្នាំ) ចំនួន ១១ពេល ក្នុងមួយឆ្នាំសិក្សា និងផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀនដែលបានបង្រៀនម៉ោងបន្ថែមសម្រាប់ជួយសិស្សនៅថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំសិក្សាចំនួន ១០.០០០រៀល ក្នុងមួយពេលក្នុងមួយនាក់ ដោយគិតទាំងអ្នកគ្រប់គ្រងបណ្ណារក្ស រោងជាង និងលេខាធិការ(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០០៧ ទំព័រ៣)។

### ២.២.៧ ការកសាងផែនការអភិវឌ្ឍសាលារៀន

ដើម្បីកសាងផែនការអភិវឌ្ឍន៍សាលារៀនមួយឲ្យមានតម្លាភាព និងទទួលបាននូវប្រសិទ្ធភាពខ្ពស់ស្របតាមសូចនាករដែលបានកំណត់ នាយកដ្ឋានបឋមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការណែនាំឲ្យគ្រប់សាលាបឋមសិក្សាក្នុងរាជធានី-ខេត្តអនុវត្ត៖ នាយកសាលាគប្បីជួបប្រជុំជាមួយលោកគ្រូ-អ្នកគ្រូ ក្រុមប្រឹក្សាឃុំ/សង្កាត់ គណៈកម្មការទ្រទ្រង់សាលា សិស្ស និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បី៖ រកបញ្ហាទាំងអស់របស់សាលា ធ្វើការជ្រើសរើសបញ្ហាចំបងពី២ ទៅ៣ដែលចាំបាច់ យកបញ្ហាចំបងទាំងនោះមកវិភាគរកមូលហេតុតាមបែបដើមឈើបញ្ហា ធ្វើការជ្រើសរើសបញ្ហាជាអាទិភាព ប្តូរឃ្លាបញ្ហាទាំងនោះទៅជាឃ្លាវត្ថុបំណង រៀបចំវត្ថុបំណងទៅតាមសមាសភាគទាំង៦ដែលមានចែងនៅក្នុងឯកសារកម្មវិធីសាលាកុមារមេត្រី (១-កុមារទាំងអស់បានចូលរៀន ២-ការសិក្សាប្រកបដោយប្រសិទ្ធភាព ៣-សុខភាព សុវត្ថិភាព និងការការពារកុមារ ៤-ការឆ្លើយតបទៅនឹងយេនឌ័រ ៥-ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ និង៦-ការគាំទ្រពីប្រព័ន្ធអប់រំ) រកសកម្មភាពដើម្បីសម្រេចបំណង កំណត់ធនធានដែលបំរើឲ្យសកម្មភាពនីមួយៗ (មនុស្ស ថវិកា សម្ភារ) សរសេរសូចនាករដើម្បីឲ្យឆ្លើយតបជាមួយនឹងវត្ថុបំណង(ដោយគោរពធាតុទាំងបីគឺ៖ អ្វី? ប៉ុន្មាន? ពេលណា?) កែលម្អផែនការអភិវឌ្ឍព្រាងឲ្យសមស្របរវាងសូចនាករ ធនធាន សកម្មភាព និងវត្ថុបំណង រៀបចំតារាងកាលវិភាគសម្រាប់អនុវត្ត(ប្រតិទិនការងារ) បញ្ជូនផែនការដើម្បីសុំការយល់ព្រមតាមឋាននុក្រម(សហគមន៍ ប្រធានកម្រង ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌ) អនុវត្តតាមផែនការដោយមានការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធ និងវាយតម្លៃលទ្ធផលនៃការអនុវត្តន៍ផែនការតាមដំណាក់ៗ និងដំណាច់ឆ្នាំសិក្សា(នាយកដ្ឋានបឋមសិក្សា ២០១១ ទំព័រ ១៧)។

## ២.៣ បញ្ហាប្រឈមក្នុងការងារគ្រប់គ្រង និងអនុវត្តថវិកាកន្លងមក

រយៈពេលបីឆ្នាំកន្លងមក ការអនុវត្តថវិកាកម្មវិធីមិនទាន់ឆ្លើយតបទៅនឹងផែនការដែលកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់នៅឡើយទេ (៩៥%) (ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣)។ ការចំណាយថវិកាកម្មវិធីពីមួយឆ្នាំទៅមួយឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡាពុំដែលអស់ឡើយ។ នាឆ្នាំដំបូងនៃការអនុវត្តថវិកាកម្មវិធី(២០០៧) ក្រសួងអប់រំ យុវជន និងកីឡាសម្រេចលទ្ធផលបាន ៦២.១% ឆ្នាំ២០០៨បានចំនួន ៨១.៨% ឆ្នាំ២០០៩បានចំនួន ៨៩.៩% ឆ្នាំ២០១០បានចំនួន ៩១.៣% និងឆ្នាំ២០១១បានចំនួន ៩១.៧%(របាយការណ៍ក្រសួងអប់រំ ២០១២)។ តាមរយៈលទ្ធផលនេះបង្ហាញថា ការអនុវត្តថវិកាកម្មវិធីពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើង ប៉ុន្តែប្រសិនបើធៀបនឹងចំណុចដៅដែលបានកំណត់គឺនៅទាបនៅឡើយ។"លទ្ធផលនៃការអនុវត្តថវិកានេះនឹងនាំទៅរកហានិភ័យមួយសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ពីព្រោះថាកម្រិតនៃការជួយគាំទ្រមូលនិធិប្បទានពីដៃគូអភិវឌ្ឍន៍មួយចំនួនដូចជាសហគមន៍អឺរ៉ុប(EU) ត្រូវផ្អែកលើលទ្ធផលនៃការចំណាយរបស់ក្រសួង ប្រសិនបើក្រសួងអនុវត្តចំណាយបានតិច នោះចំនួនថវិកាគាំទ្រដែលដៃគូអភិវឌ្ឍន៍ផ្តល់ជូននឹងត្រូវកាត់បន្ថយ។ ដូច្នេះ ការទូទាត់ចំណាយថវិកាកម្មវិធីឲ្យបានពេញលេញ គឺធានានូវអតិបរមានៃថវិកាជំនួយដែលបានមកពីដៃគូអភិវឌ្ឍផងដែរ។ ចំពោះបញ្ហានេះ គឺជាការចាំបាច់បំផុតដែលក្រសួងអប់រំ យុវជន និងកីឡា ត្រូវជំរុញការទូទាត់ចំណាយនៅគ្រប់អង្គភាពអនុវត្តថវិកាទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យកាន់តែប្រសើរឡើង ដើម្បីឈានទៅដល់ចំណុចដៅ ជាពិសេសនៅកម្រិតរាជធានី-ខេត្តដែលមួយផ្នែកធំនៃថវិកាកម្មវិធីនេះត្រូវបានចំណាយ ហើយដែលភាគច្រើននៃថវិកាត្រូវបានចំណាយនៅកម្រិតសាលារៀន ដូចជា ថវិកាសម្រាប់ដំណើរការសាលារៀនជាដើម"(សុន្ទរកថារបស់ឯកឧត្តម ជា អឿង អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ២០០៩)។

ថវិកាកម្មវិធីដែលបាន និងកំពុងដំណើរការអនុវត្តសព្វថ្ងៃទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិកំពុងជួបប្រទះនូវបញ្ហាប្រឈមជាច្រើនក្នុងការអនុវត្ត ជាពិសេស ពាក់ព័ន្ធទៅនឹងនីតិវិធីនៃការទូទាត់ថវិការជួទេយ្យបុរេប្រទាន ដែលទាមទារនូវកិច្ចសហប្រតិបត្តិការ និងការប្តេជ្ញាយ៉ាងពេញទំហឹងពីគ្រប់នាយកដ្ឋានជំនាញ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ពិសេសនៅកម្រិតសាលារៀន ដើម្បីពង្រឹងការងារគ្រប់គ្រង និងអនុវត្តថវិកាឲ្យកាន់តែល្អប្រសើរស្របតាមផែនការយុទ្ធសាស្ត្រ និងសូចនាករដែលក្រសួងបានគ្រោង(នាយកដ្ឋានហិរញ្ញវត្ថុ ២០០៩)។ តើសាលារៀនមានបញ្ហាប្រឈមអ្វីខ្លះដែលរាំងស្ទះដល់ដំណើរការការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធី?

តាមរយៈរបាយការណ៍របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត សាលារៀនមានបញ្ហាប្រឈមជាច្រើនដែលរាំងស្ទះដល់ដំណើរការការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធី ជាពិសេសបញ្ហាការទូទាត់ថវិកា។ សាលារៀនគ្មានគណនេយ្យករដែលជាការលំបាកក្នុងការចុះកិច្ចបញ្ជិកាគណនេយ្យ នាយកសាលាមិនបានចាត់ចែងចំណាយជាបន្ទាន់ក្រោយពេលបានទទួល

សាច់ប្រាក់ពីការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌ នាយកសាលាពុំបានតាមដានការងារទូទាត់ថវិកា កង្វះថវិកាសម្រាប់ទូទាត់ថ្លៃទឹក-ភ្លើង សាលារៀនមួយចំនួនបានមកកែឯកសារទូទាត់នៅមន្ទីររួចហើយ ប៉ុន្តែឯកសារដែលតម្កល់នៅអង្គភាពសាមីពុំបានកែ(មន្ទីរអយក.រាជធានីភ្នំពេញ ២០១០) សាលាផ្តល់របាយការណ៍ជូនការិយាល័យអប់រំស្រុកពុំទាន់ពេលវេលា នាយក និងហេរញ្ញឹកសាលាមិនទាន់យល់ច្បាស់ពីកិច្ចបញ្ជិកាគណនេយ្យ សាលាមួយចំនួនពុំមានផែនការអភិវឌ្ឍសាលារៀន បុគ្គលិកសិក្សាមិនគ្រប់គ្រាន់ ពិបាកក្នុងការរៀបចំគណៈកម្មកាគ្រប់គ្រង និងអនុវត្តថវិកា កញ្ចប់ថវិកាដំណើរការសាលាមិនទាន់សមស្របតាមទំហំសកម្មភាពរបស់សាលា (មន្ទីរអយក.ខេត្តស្ទឹងត្រែង ២០១០) សាលាមួយចំនួនមិនទាន់យល់ច្បាស់ពីមាតិកាចំណាយថវិកា សហគមន៍និងអាជ្ញាធរដែនដីពុំមានជំហរចូលរួមការងារអប់រំឲ្យបានផុសផុលនៅឡើយ ការទម្លាក់ឥណទានក្នុងមួយឆ្នាំពីរដងពិបាកក្នុងការចំណាយ និងទូទាត់ថវិកា(មន្ទីរអយក.ខេត្តកណ្តាល ២០១០) ការយល់ដឹងរបស់នាយកសាលានៅមានកម្រិត សាលារៀនមានសក្ខីប័ត្រច្រើនក្នុងការទូទាត់ សាលាគ្មានបណ្តាញអគ្គិសនីប៉ុន្តែផ្តល់ថវិកាឲ្យចំណាយថ្លៃអគ្គិសនី ជាហេតុធ្វើឲ្យថវិកាសល់មិនអាចចំណាយបាន(មន្ទីរអយក.ខេត្តកំពង់ស្ពឺ ២០១០) ការទម្លាក់ថវិកាឲ្យសាលាអនុវត្តសកម្មភាពលើអនុគណនីមួយចំនួនពុំទាន់សមស្របតាមតម្រូវការរបស់សាលា សាលាមួយចំនួនផ្លាស់ប្តូរនាយកនិងហេរញ្ញឹកញឹកញ៉ាប់ សាលាខ្លះនាយកបោះបង់ការងារដោយមិនរវល់នឹងការងារទូទាត់ថវិកា រីឯការរៀបចំឯកសារទូទាត់មិនត្រូវតាមគោលការណ៍ណែនាំ ការអនុវត្តកិច្ចបញ្ជិកាគណនេយ្យនៅតាមសាលារៀនមួយចំនួនមានកំហុសច្រើន សាលាមួយចំនួនរក្សាសម្ភារ ថវិកា និងឯកសារផ្សេងៗនៅឯផ្ទះនាយក គ្រប់សម្ភារបរិក្ខា និងសង្ហារឹមនៅសាលាមួយចំនួនពុំបានដាក់ឈ្មោះថវិកាកម្មវិធីនិងកាលបរិច្ឆេទនៃឆ្នាំ(មន្ទីរអយក.ខេត្តកោះកុង ២០១០) សមត្ថភាពរបស់នាយក និងហេរញ្ញឹកសាលាមួយចំនួននៅមានកម្រិត ហើយពុំទាន់យល់ច្បាស់ពីនីតិវិធីនៃការអនុវត្តថវិកាកម្មវិធី ការផ្តល់សៀវភៅណែនាំក្នុងការអនុវត្តថវិកាកម្មវិធីរបស់នាយកដ្ឋានជំនាញពុំទាន់ពេលវេលា ដែលធ្វើឲ្យការអនុវត្តសកម្មភាពមានការលំបាក(មន្ទីរអយក.ខេត្តសៀមរាប ២០១០) សាលារៀនពុំបានរៀបចំផែនការថវិកាជាមុន នៅពេលទទួលបានថវិកាទើបរៀបចំដោយតម្រូវតាមថវិកាដែលបានទទួល(មន្ទីរអយក.ខេត្តកែប២០១០) ការប្រើប្រាស់ថវិកាកម្មវិធីនៅសាលាមួយចំនួនពុំសូវមានតម្លាភាព នាយកសាលាខ្លះពុំសូវយកចិត្តទុកដាក់ស្វែងយល់ពីការចុះកិច្ចបញ្ជិកាគណនេយ្យ ជាហេតុធ្វើឲ្យមានកំហុសច្រើន(មន្ទីរអយក.ខេត្តតាកែវ ២០១០) កង្វះធនធានមនុស្សក្នុងការបំពេញការងារ សាច់ប្រាក់មាននៅក្នុងបេឡាប៉ុន្តែនាយកសាលាមួយចំនួនពុំព្រមធ្វើផែនការដើម្បីដកសាច់ប្រាក់យកទៅចំណាយ សាលាមួយចំនួនទៀតបានចំណាយថវិកាហើយប៉ុន្តែមិនព្រមរៀបចំឯកសារទូទាត់ ការចំណាយថវិកាកម្មវិធីនៅសាលាមួយចំនួននាយកសាលាច្រើនអត្តនោម័តិ គ្មានការប្រជុំគ្រូឬគណៈកម្មការសាលារៀន ជាហេតុធ្វើឲ្យការចំណាយមិនចំគោលដៅ ដែលប្រាសចាកពីផែនការអភិវឌ្ឍសាលារៀន(មន្ទីរអយក.ខេត្តឧត្តរមានជ័យ

២០១០) សាលាមិនទាន់យល់ច្បាស់ពីខ្ទង់ចំណាយនៃអនុគណនីនីមួយៗ ការបញ្ជូនឯកសារទូទាត់ត្រឡប់ឲ្យសាលារៀនកែសម្រួលនូវកំហុសឆ្គងទាមទាររយៈពេលយូរ សាលារៀនមួយចំនួនមានបុគ្គលិកតែម្នាក់ត្រូវបង្រៀនផង និងរៀបចំឯកសារទូទាត់ផង គណៈគ្រប់គ្រងថវិកាមួយចំនួនពុំបានស្វែងយល់ពីតួនាទី ភារកិច្ចរបស់ខ្លួនឲ្យបានច្បាស់លាស់ ជាហេតុនាំឲ្យការគ្រប់គ្រង និងអនុវត្តថវិកាមានការឆកល្វែង សាលាមួយចំនួនពុំមានតម្លាភាពក្នុងការងារគ្រប់គ្រង ដោយហេតុថាពេលដកសាច់ប្រាក់ និងពេលចំណាយមិនបានប្រជុំគណៈកម្មការគ្រប់គ្រងថវិកា លោកគ្រូ អ្នកគ្រូ (មន្ទីរអយក.ខេត្តស្វាយរៀង ២០១០) មន្ត្រីជំនាញនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការចុះពិនិត្យតាមដាន ឬណែនាំពីការអនុវត្តថវិកាកម្មវិធីនៅតាមសាលារៀនដែលនៅឆ្ងាយ(មន្ទីរអយក.ខេត្តកំពត ២០១០) ការបណ្តុះបណ្តាលរបស់ក្រសួងតម្រូវឲ្យនាយកសាលាចូលរួម នៅពេលនាយកមិននៅ អ្នកទទួលបន្ទុកបន្តមិនយល់ពីការងារដែលត្រូវធ្វើ ការប្រមូលរបាយការណ៍ទូទាត់ពីសាលារៀនមានការយឺតយ៉ាវ សាលាមួយចំនួនសហគមន៍មិនសូវចូលរួមក្នុងការងារថវិកាកម្មវិធីឡើយដោយសារជីវភាពខ្វះខាត(មន្ទីរអយក.ខេត្តបន្ទាយមានជ័យ ២០១០)។ តើទាំងនេះជាបញ្ហាប្រឈមពិតប្រាកដដែលសាលាបាន និងកំពុងជួបប្រទះ?

យោងតាមការធ្វើអង្កេតរបស់ក្រុមគ្រូតពិនិត្យចំណាយសាធារណៈ(PETS) ឆ្នាំ២០០៦ លើការអនុវត្តថវិកាPAPនៅសាលាបឋមសិក្សាបានបង្ហាញថា ក្នុងការបើកផ្តល់សាច់ប្រាក់ពីរតនាគារខេត្តទៅដល់សាលារៀនត្រូវបាត់បង់ថវិកាអស់ប្រហែលជា ២% នៃថវិកាសរុប។ ថវិកា២%នេះ គឺជាថ្លៃសម្រាប់សម្រួលការងារឯកសារ និងការបើក-ផ្តល់សាច់ប្រាក់ពីរតនាគាររាជធានី-ខេត្ត ទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងពីមន្ទីរអប់រំរាជធានី-ខេត្តទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងពីការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ ទៅសាលារៀន(Kimchoeun, P. 2006)។ ចុះចំណែកបច្ចុប្បន្ននេះវិញ ក្នុងការអនុវត្តថវិកាកម្មវិធី តើការកាត់ភាគរយនេះនៅមានបន្តទៀតដែរឬទេ? ប្រសិនបើមាន តើសាលារៀនត្រូវបាត់បង់អស់ថវិកាចំនួនប៉ុន្មានភាគរយនៃថវិកាសរុបដែលទទួលបាន ដើម្បីជាថ្លៃរក្នុងការរត់ឯកសារ និងការបើកសាច់ប្រាក់យកទៅចំណាយអនុវត្តសកម្មភាព?

# ជំពូកទី ៣
# វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ជំពូកនេះនឹងបរិយាយអំពីវិធីសាស្ត្រនៃការជ្រើសរើសប្រភេទគំរូ(Sampling) របៀបប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ដែលនឹងត្រូវប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ។ នៅក្នុងជំពូកនេះផងដែរ នឹងមានការរៀបរាប់អំពីដែនកំណត់នៃវិធីសាស្ត្រដែលនឹងយកមកប្រើប្រាស់សម្រាប់ការសិក្សាស្រាវជ្រាវ ព្រមទាំងមានការបរិយាយអំពីបញ្ហាក្រមសីលធម៌ដែលនឹងកើតមានឡើងនៅក្នុងពេលកំពុងធ្វើការសិក្សាស្រាវជ្រាវ។

ការសិក្សាស្រាវជ្រាវនេះ នឹងរៀបចំឡើងដោយមានការចូលរួមពី គណៈគ្រប់គ្រងសាលា ហេរញ្ញិក លោកគ្រូ អ្នកគ្រូដែលបង្រៀននៅសាលាបឋមសិក្សាក្រាំងធ្នុងដែលគណៈគ្រប់គ្រងសាលាជាយេនឌ័រនិងជាប្រធានកម្រង គណៈកម្មាការទ្រទ្រង់សាលារៀន មាតាបិតាសិស្ស មន្ត្រីការិយាល័យអប់រំខណ្ឌ មន្ត្រីការិយាល័យបឋមសិក្សា និងមន្ត្រីការិយាល័យគណនេយ្យនៃមន្ទីរអប់រំ យុវជននិងកីឡារាជធានី-ខេត្ត ព្រមទាំងមន្ត្រីនៃនាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានហិរញ្ញវត្ថុ (ការិយាល័យហិរញ្ញវត្ថុផ្នែកខេត្ត-ក្រុង)នៃក្រសួងអប់រំ យុវជន និងកីឡា។

## ៣.១ ប្រភេទប្រធានបទ

ការសិក្សាស្រាវជ្រាវនេះ ជាការសិក្សាតាមបែបគុណវិស័យ(Qualitative Method) ពីព្រោះវិធីសាស្ត្រនេះសាកសមបំផុត ក្នុងការនិយាយរៀបរាប់អំពីបញ្ហាប្រឈម និងការយល់ឃើញរបស់អ្នកដែលនឹងត្រូវបានសម្ភាសន៍។ ជាងនេះទៅទៀត ការសិក្សានេះ ជាការសិក្សាដើម្បីឲ្យបានដឹងប្រាកដពីលក្ខណៈពិសេសនៃអាណត្តិនីមួយៗដែលជាបញ្ហាប្រឈមក្នុងការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅសាលាបឋមសិក្សា ។ ជាមួយគ្នានេះដែរ ក៏ដើម្បីផ្តល់នូវព័ត៌មានដែលជាចំណុចខ្សោយ និងការលំបាកទាំងឡាយដែលមានទំនាក់ទំនងគ្នាទៅនឹងអាណត្តិទាំងនោះ រួចធ្វើការវិភាគប្រៀបធៀបទិន្នន័យ ដើម្បីទាញរកការសន្និដ្ឋាន និងព្យាយាមលើកឡើងជាអនុសាសន៍មួយចំនួនដែលជាប្រយោជន៍ដល់ការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅសាលាបឋមសិក្សា។

## ៣.២ ឧបករណ៍ប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យ

ក្នុងការប្រមូលទិន្នន័យ ឧបករណ៍មួយចំនួនត្រូវបានប្រើប្រាស់ដែលរួមមាន៖ កម្រងសំណួរសម្រាប់ធ្វើការសម្ភាសន៍ ឧបករណ៍ថតសម្លេង ទូរស័ព្ទ កុំព្យូទ័រ លិខិតស្នើសុំការអនុញ្ញាតចុះធ្វើការសិក្សាស្រាវជ្រាវពីគណៈគ្រប់គ្រងសាលាបឋមសិក្សាក្រាំងធ្នុង និងពីគណៈគ្រប់គ្រងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ ព្រមទាំងលិខិតស្នើសុំការអនុញ្ញាតពីអ្នកដែលនឹងត្រូវសម្ភាសន៍(Consens Form) ជាដើម។

## ៣.៣ ការជ្រើសរើសគំរូ ឬសំណាក(Sampling)

នៅក្នុងការសិក្សាស្រាវជ្រាវនេះ គំរូងាយស្រួល(Convenience Sampling) នឹងត្រូវជ្រើសរើសយកមកប្រើប្រាស់ ពីព្រោះអ្នកចូលរួមទាំងអស់នឹងស្ម័គ្រចិត្ត ហើយត្រៀមខ្លួនជាស្រេចដើម្បីចូលរួមចែករំលែកនូវបទពិសោធន៍ និងការយល់ឃើញរបស់ពួកគាត់អំពីបញ្ហាប្រឈមក្នុងការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅសាលាបឋមសិក្សា។ ក៏ប៉ុន្តែលទ្ធផលនៃការសិក្សានេះនឹងមិនអាចយកមកតំណាង ឬបញ្ជាក់ជាលក្ខណៈទូទៅសម្រាប់លោកគ្រូ អ្នកគ្រូ និងអ្នកចូលរួមសម្ភាសន៍ទាំងអស់បានទេ ពីព្រោះចំនួនអ្នកដែលនឹងត្រូវសម្ភាសន៍តិច ម្យ៉ាងទៀត ពួកគាត់សុទ្ធតែជាអ្នកស្ម័គ្រចិត្តចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ(Rina.B, 2011)។

អ្នកដែលនឹងត្រូវបានជ្រើសរើសឲ្យចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះសរុបមានចំនួន២០នាក់ដែលរួមមាន៖ គណៈគ្រប់គ្រងសាលា០១នាក់ ហេរញ្ញិកសាលា០១នាក់ លោកគ្រូ អ្នកគ្រូដែលបង្រៀននៅសាលាបឋមសិក្សាក្រាំងធ្នុង០៤នាក់ គណៈកម្មការទ្រទ្រង់សាលារៀន០១នាក់ មាតាបិតាសិស្ស០២នាក់ មន្ត្រីការិយាល័យអប់រំខណ្ឌ០១នាក់ មន្ត្រីការិយាល័យបឋមសិក្សានៃមន្ទីរអប់រំរាជធានីភ្នំពេញ០១នាក់ មន្ត្រីការិយាល័យគណនេយ្យនៃមន្ទីរអប់រំរាជធានីភ្នំពេញ០១នាក់ មន្ត្រីនាយកដ្ឋានបឋមសិក្សានៃក្រសួងអប់រំ០១នាក់ និងមន្ត្រីការិយាល័យហិរញ្ញវត្ថុផ្នែកខេត្ត-ក្រុងនៃនាយកដ្ឋានហិរញ្ញវត្ថុ០១នាក់ ព្រមទាំងមន្ត្រីការិយាល័យគណនេយ្យនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តដែលអត្រានៃការអនុវត្តថវិកាកម្មវិធីមានកម្រិតខ្ពស់ចំនួន០២នាក់(០២ខេត្ត) កម្រិតមធ្យម ០២នាក់(០២ខេត្ត) និងកម្រិតទាប០២នាក់(០២ខេត្ត)។ ការជ្រើសរើសនេះគឺផ្អែកតាមរបាយការណ៍សម្រេចទូទាត់របស់នាយកដ្ឋានហិរញ្ញវត្ថុឆ្នាំ២០១១។

មូលហេតុនៃការជ្រើសរើសអ្នកដែលនឹងត្រូវចូលរួមសម្ភាសន៍ទាំង២០នាក់នេះមកសិក្សាស្រាវជ្រាវ ពីព្រោះ ទី១-ពួកគាត់ទាំងអស់សុទ្ធតែមានទំនាក់ទំនងរវាងគ្នានិងគ្នា និងជាអ្នកចូលរួមអនុវត្តផ្ទាល់ក្នុងការងារគ្រប់គ្រង រៀបចំផែនការ បែងចែកនិងបើកផ្តល់ថវិកា ជាពិសេសជាអ្នកចំណាយថវិកាផ្ទាល់។ ទី២-ដើម្បីស្វែងរកទិន្នន័យឲ្យកាន់តែច្បាស់បន្ថែមទៀត និងទី៣-ដើម្បីស្វែងរកឲ្យឃើញនូវឧបសគ្គនៃបញ្ហាជាក់លាក់មួយ ពីព្រោះថា រាល់បញ្ហាដែលកើតមានឡើងចំពោះការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀន មិនមែនមកតែពីគណៈគ្រប់គ្រងសាលាទាំងស្រុងនោះទេ ប៉ុន្តែប្រហែលជាមានកត្តាពាក់ពន្ធ័មួយចំនួនផ្សេងទៀត ដែលជំរុញឲ្យការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀននេះ មិនអាចសម្រេចបានតាមគោលដៅកំណត់។ ជារួម តើក្នុងចំណោមអ្នកពាក់ពន្ធ័ទាំងអស់ ផ្នែកណាមួយដែលជះឥទ្ធិពលទៅលើបញ្ហាប្រឈមនៃការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀនខ្លាំងជាងគេ?

Random Selection នឹងត្រូវបានប្រើប្រាស់ដើម្បីជ្រើសរើសអ្នកដែលនឹងត្រូវសម្ភាសន៍ដោយការសរសេរឈ្មោះអ្នកពាក់ព័ន្ធទាំងអស់ដាក់ក្នុងប្រអប់មួយ រួចក្រឡុក ហើយចាប់យកម្តងមួយៗរហូតគ្រប់ចំនួនតាមតម្រូវការ។

## ៣.៤ ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើបញ្ហាប្រឈមនៃការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅសាលាបឋមសិក្សា ប៉ុន្តែដោយសាលាបឋមសិក្សាទូទាំងប្រទេសមានវិសាលភាពធំទូលាយពេក(៦.៧៦៧សាលា-EMIS 2011) ដូច្នេះ ករណីសិក្សាស្រាវជ្រាវនេះ ត្រូវបានជ្រើសរើសតែមួយសាលាបឋមសិក្សាប៉ុណ្ណោះ គឺសាលាបឋមសិក្សាក្រាំងធ្នុង ដែលស្ថិតនៅសង្កាត់ក្រាំងធ្នុង ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ផែនទីសិក្សារបស់សាលាបឋមសិក្សាក្រាំងធ្នុងគ្របដណ្តប់ភូមិសិក្សាចំនួន ៩ និងសហគមន៍ចំនួន ២។ សាលាមានអគារសិក្សាចំនួន ៣ខ្នង និងបន្ទប់សិក្សាចំនួន ១៣បន្ទប់ ក្នុងនោះមានអគារទ្រុឌទ្រោមចំនួន១ខ្នងដែលមាន៥បន្ទប់កំពុងស្នើសុំរុះរើ។ បឋមសិក្សាក្រាំងធ្នុងមាន៧ថ្នាក់ ពីថ្នាក់ទី១ដល់ថ្នាក់ទី៦ និងមានថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់ចំនួន០១ថ្នាក់ផងដែរ។ សិស្សសរុបសម្រាប់ឆ្នាំសិក្សា២០១១-២០១២នេះ មានចំនួន ៦០១នាក់ ស្រី២៨៦នាក់ ក្នុងនោះសិស្សជួបការលំបាកមានចំនួន៨១នាក់ ស្រី៤២នាក់។ សាលាបឋមសិក្សាក្រាំងធ្នុងមានគណៈគ្រប់គ្រងចំនួន ០២នាក់(នាយិកា និងនាយករង) បុគ្គលិកជំនាញ ០១នាក់(បណ្ណារក្ស) និងបុគ្គលិកបង្រៀនចំនួន ១២នាក់ ស្រី ០៦នាក់។

## ៣.៥ ការប្រមូលទិន្នន័យ

### ៣.៥.១ ទិន្នន័យទី១

សម្រាប់ការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យនេះ គឺមានវិធីជាច្រើនក្នុងការប្រមូលទិន្នន័យដូចជា កម្រងសំណួរ ការអង្កេត ការសម្ភាសន៍ ឯកសារផ្លូវការ រូបថត ការថតសម្លេង ការប្រើទូរស័ព្ទសម្រាប់ទំនាក់ទំនង ការផ្ញើសារ ការសន្ទនាក្រៅផ្លូវការជាដើម។ ម្យ៉ាងវិញទៀត វិធីសាស្រ្តទាំងអស់នេះ គឺជាវិធីសាស្រ្តដែលសំខាន់ និងឆ្លុះបញ្ចាំងពីលក្ខណៈធម្មជាតិផ្សេងៗគ្នានៃទិន្នន័យដែលប្រមូលបាន (Rina.B, 2011)។

នៅក្នុងការសិក្សាស្រាវជ្រាវនេះ ការសម្ភាសន៍នឹងត្រូវបានជ្រើសរើសយកមកប្រើប្រាស់ដោយប្រើកម្រងសំណួរសម្រាប់សម្ភាសន៍។

#### ៣.៥.១.១ កម្រងសំណួរ

កម្រងសំណួរនឹងត្រូវបានរៀបចំជាប្រភេទសំណួរបើកដែលជាប្រភេទសំណួរសួរឲ្យគេឆ្លើយនូវអ្វីដែលយើងបានសួរ ហើយកម្រងសំណួរនេះនឹងត្រូវបានរៀបចំទៅតាមប្រភេទនៃអ្នកដែលនឹងត្រូវសួរ។

#### ៣.៥.១.២ ការសម្ភាសន៍

ការសម្ភាសន៍បុគ្គល ត្រូវបានប្រើប្រាស់យ៉ាងញឹកញ៉ាប់នៅក្នុងការសិក្សាស្រាវជ្រាវ

តាមបែបគុណវិស័យ ពីព្រោះការសម្ភាសន៍បុគ្គលម្នាក់ៗជួយឲ្យអ្នកសិក្សាស្រាវជ្រាវអាចទទួលបាននូវព័ត៌មានដែលច្បាស់លាស់ និងមានប្រយោជន៍ តាមរយៈការនិយាយសន្ទនាគ្នាជាមួយមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ម្យ៉ាងវិញទៀត ការសម្ភាសន៍អាចផ្តល់ព័ត៌មានដែលទាក់ទងទៅនឹងចរិតលក្ខណៈរបស់មនុស្ស ការឲ្យតម្លៃរបស់ពួកគេ អ្វីដែលពួកគេគិតនិងធ្វើ និងអារម្មណ៍ ឬការយល់ឃើញរបស់ពួកគេចំពោះអ្វីមួយ (Rina.B, 2011)។

ទោះជាយ៉ាងណាក៏ដោយ ការសម្ភាសន៍ក៏ជាប្រភពទិន្នន័យមួយដែលមានដែនកំណត់ផងដែរ។ រាល់ចម្លើយដែលផ្តល់ឲ្យនៅពេលសម្ភាសន៍ ជូនកាលផ្ទុយពីអ្វីដែលអ្នកសិក្សាចង់បាន ពីព្រោះអ្នកដែលត្រូវសម្ភាសន៍ ពេលខ្លះបង្ហាញពីគំនិតអត្តនោម័តលើការងារអ្វីមួយដែលគេចង់ឲ្យអ្នកសិក្សាដឹង និងពីអ្វីមួយទៀតដែលគេគិតថា អ្នកសិក្សាចង់ដឹង(Rina.B, 2011)។

### ៣.៥.២ ទិន្នន័យទី២

ការសិក្សាស្រាវជ្រាវនេះ ភាគច្រើនត្រូវចំណាយពេលវេលាជាច្រើនក្នុងការប្រមូលទិន្នន័យដែលជាប្រភេទទិន្នន័យទី២ (Secondary data) មកធ្វើការវិភាគ ដើម្បីសិក្សាទៅលើប្រធានបទ។ ទិន្នន័យនេះគឺជាទិន្នន័យដែលមានស្រាប់ បានមកតាមរយៈឯកសារដែលជារបាយការណ៍ សារាចរណែនាំ សេចក្តីណែនាំ គោលការណ៍ណែនាំ និងឯកសារផ្សេងៗជាច្រើនទៀត ដែលពាក់ព័ន្ធដល់ការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅសាលាបឋមសិក្សា។ ចំពោះឯកសារដែលជារបាយ-ការណ៍សិក្សា(Research Report) ឬនិក្ខេបបទ(Thesis) ដែលសរសេរពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀននេះ ពិតជាកម្រណាស់ ពីព្រោះថា ប្រធានបទនេះ ពុំទាន់មានអ្នកណាសរសេរឲ្យបានស៊ីជម្រៅ និងផ្តោតអារម្មណ៍ខ្លាំងនៅឡើយទេ ដែលជាហេតុធ្វើឲ្យការសិក្សានេះមានការពិបាកខ្លាំងក្នុងការស្វែងរកឯកសារមកយោង និងមកសិក្សា។ ការវិភាគទិន្នន័យផ្សេងៗគឺផ្តោតធ្ងន់តែទៅលើឯកសារដែលជារបាយការណ៍របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងគោលការណ៍ណែនាំមួយចំនួនរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានជំនាញមួយចំនួន តែប៉ុណ្ណោះ។

## ៣.៦ ការវិភាគទិន្នន័យ

បន្ទាប់ពីទិន្នន័យត្រូវបានប្រមូល ការវិភាគទិន្នន័យតាមបែបគុណវិស័យនឹងត្រូវបានប្រើប្រាស់សម្រាប់វិភាគសម្តីដែលទទួលបានតាមរយៈការសម្ភាសន៍ ដោយការស្រង់សម្តីដែលមានប្រភេទដូចគ្នា ហើយធ្វើការបែងចែកប្រភេទនៃក្រុមបញ្ហា ដោយបញ្ចូលក្នុងតារាងមួយ ដើម្បីងាយស្រួលធ្វើការវិភាគទៅលើសម្តីទាំងនោះ ដែលជាកត្តាប្រឈមទាំងឡាយណាដែលរាំងស្ទះដល់ដំណើរការការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀន។

## ៣.៧ ក្រមសីលធម៌ក្នុងការសិក្សាស្រាវជ្រាវ

ក្រមសីលធម៌ពិតជាមានសារៈសំខាន់ណាស់ក្នុងការសិក្សាស្រាវជ្រាវដែលទាមទារឲ្យអ្នកសិក្សាទាំងអស់ត្រូវតែអនុវត្តដោយខានមិនបាន។ មុននឹងចាប់ផ្ដើមធ្វើការសម្ភាសន៍ ក្នុងនាមជាអ្នកស្រាវជ្រាវមួយរូប គប្បីសុំការអនុញ្ញាតយល់ព្រមជាមុនសិនពីសាមីជនដោយផ្ទាល់ និងដោយស្ម័គ្រចិត្ត មកចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។ លិខិតយល់ព្រម(Consent Form) ពីអ្នកដែលនឹងត្រូវសម្ភាសន៍ នឹងត្រូវបានរៀបចំឡើងដើម្បីចែកជូនដល់អ្នកចូលរួមទាំងអស់ ហើយរាល់ព័ត៌មានដែលនឹងប្រមូលបាន និងលទ្ធផលទាំងប៉ុន្មានដែលនឹងបានមកពីកិច្ចសម្ភាសន៍ នឹងត្រូវបានរក្សាជាការសម្ងាត់។ ក្នុងករណីមានថតជាខ្សែអាត់សម្លេង នឹងត្រូវបានបំផ្លាញចោល ឬក៏ប្រគល់ឲ្យម្ចាស់ដើមវិញ គឺនៅក្រោយពេលដែលការវិភាគទិន្នន័យត្រូវបានបញ្ចប់ជាស្ថាពរ។ ការធ្វើបែបនេះ គឺដើម្បីរក្សាទំនុកចិត្តរវាងអ្នកសម្ភាសន៍ និងអ្នកដែលនឹងត្រូវបានសម្ភាសន៍។ម្យ៉ាងវិញទៀត គឺអាចរក្សារាល់ព័ត៌មានដែលលោកគ្រូ អ្នកគ្រូ និងមន្ត្រីពាក់ព័ន្ធទាំងអស់បានផ្ដល់ឲ្យ ជាការសម្ងាត់។ រីឯអត្តសញ្ញាណផ្សេងៗរបស់លោកគ្រូ អ្នកគ្រូ និងមន្ត្រីទាំងអស់នឹងមិនត្រូវបានបង្ហាញឲ្យឃើញនៅពេលវិភាគទិន្នន័យ ឬដាក់នៅក្នុងរបាយការណ៍ដោយគ្មានការអនុញ្ញាតពីសាមីជនឡើយ។

លើសពីនេះ ការសិក្សាស្រាវជ្រាវនេះ គឺធ្វើឡើងដោយគ្រាន់តែចង់បំពេញនូវតម្រូវការបញ្ចប់ការសិក្សាតែប៉ុណ្ណោះ មិនមានបំណងអ្វីធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ ចិត្តបុគ្គល ឬស្ថាប័នណាមួយឡើយ។ ជាងនេះទៅទៀត មុននឹងដំណើរការសិក្សាស្រាវជ្រាវ និងការប្រមូលទិន្នន័យ លិខិតស្នើសុំការអនុញ្ញាតពីគណៈគ្រប់គ្រងសាលាបឋមសិក្សាក្រាំងធ្នុង និងពីគណៈគ្រប់គ្រងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ នឹងត្រូវបានប្រើប្រាស់ ដើម្បីឲ្យការសិក្សាស្រាវជ្រាវនេះដំណើរការដោយភាពរលូន។

# ជំពូកទី ៤
# ការពិភាក្សា និងសេចក្ដីសន្និដ្ឋាន

## ៤.១ ការពិភាក្សា

ជារួម តាមរយៈការរៀបរាប់នៅក្នុងជំពូកទី២ "ការរំលឹកអំពីបញ្ហាប្រឈមនៃការងារគ្រប់គ្រងនិងអនុវត្តថវិកាកម្មវិធី" ខាងលើនេះ គ្រាន់តែជាចំណុចមួយចំនួនដែលបង្ហាញពីបញ្ហាប្រឈមដែលសាលាបាន និងកំពុងជួបប្រទះ ហើយដែលយើងអាចសន្និដ្ឋានបានថា៖ បញ្ហាប្រឈមដែលកើតមានឡើង គឺកើតចេញពីបញ្ហាផ្ទៃក្នុង និងបញ្ហាខាងក្រៅ។ បញ្ហាផ្ទៃក្នុងរួមមាន៖ ការគ្រប់គ្រងសមត្ថភាពមន្ត្រីទទួលបន្ទុកនិងអនុវត្តការងារ ការរៀបចំផែនការថវិកា ការរៀបចំផែនការអភិវឌ្ឍន៍សាលា ការអនុវត្តផែនការសកម្មភាពនិងការរៀបចំឯកសារទូទាត់ ធនធានមនុស្សសម្រាប់បម្រើការងារ ការទំនាក់ទំនង ការចូលរួមរបស់សហគមន៍ និងរយៈពេលនៃការចំណាយថវិកានិងការទូទាត់ឯកសារ។ រីឯបញ្ហាខាងក្រៅរួមមាន៖ ការបែងចែកនិងការបើកផ្ដល់សាច់ប្រាក់ រយៈពេលនៃការបើកផ្ដល់ថវិកា ការកសាងសមត្ថភាព គោលការណ៍ឬនីតិវិធីណែនាំក្នុងការអនុវត្តថវិកាកម្មវិធីរបស់អង្គភាពពាក់ព័ន្ធ ។

សម្រាប់ការសិក្សាស្រាវជ្រាវនេះ បញ្ហាធំៗចំនួន ០៦ នឹងត្រូវបានជ្រើសរើសយកមកសិក្សាវិភាគដែលរួមមាន៖ ការគ្រប់គ្រង ការបែងចែកថវិកា រយៈពេលនៃការដកសាច់ប្រាក់-បើកផ្ដល់-ចំណាយ-រៀបចំឯកសារទូទាត់ និងការបញ្ជូនឯកសារទូទាត់ សមត្ថភាពមន្ត្រីអនុវត្តការងារ និងការកសាងសមត្ថភាព គោលការណ៍ឬនីតិវិធីណែនាំរបស់អង្គភាពពាក់ព័ន្ធ និងការចូលរួមរបស់សហគមន៍។ ហេតុអ្វីបានជាបញ្ហាទាំង៦នេះ ត្រូវបានជ្រើសរើសយកមកសិក្សាវិភាគ?

បញ្ហាទី១៖ ការគ្រប់គ្រង។ ការគ្រប់គ្រងត្រូវបានជ្រើសរើសជាបញ្ហាទីមួយក្នុងការសិក្សាពីព្រោះថា ការអនុវត្តការចំណាយនិងការទូទាត់ថវិកាបានល្អ បានទទួលជោគជ័យ ឬមិនបាន គឺអាស្រ័យលើការគ្រប់គ្រង និងទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រង ល្អ ឬមិនល្អផងដែរ ។ ម្យ៉ាងទៀតយោងតាមរបាយការណ៍របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តមួយចំនួន ដែលលទ្ធផលនៃការអនុវត្តថវិកាកម្មវិធីទទួលបានភាគរយខ្ពស់ គឺអាស្រ័យលើការរៀបចំផែនការគ្រប់គ្រង និងអនុវត្តការងារយ៉ាងលម្អិត ចាប់តាំងពីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ផែនការថវិកា ការកំណត់រយៈពេលនៃការអនុវត្តចំណាយថវិកា និងការរៀបចំឯកសារទូទាត់ ដោយបានបែងចែកភារកិច្ចទទួលខុសត្រូវនិងតួនាទីការងារដល់មន្ត្រីក្រោមឱវាទម្នាក់ៗបានច្បាស់លាស់។ ជាងនេះទៅទៀត បានចែករំលែកព័ត៌មានដល់អ្នកពាក់ព័ន្ធទាំងអស់។ ប៉ុន្តែ តើវិធីសាស្ត្រទាំងនេះ គណៈគ្រប់គ្រងសាលារៀនផ្សេងទៀតបានអនុវត្តដែរឬទេ? ពីព្រោះកន្លងមក បញ្ហាដែលចោទខ្លាំងជាងគេគឺ ការគ្រប់គ្រងគ្មានតម្លាភាព។

បញ្ហាទី២៖ ការបែងចែកថវិកា។ ការបែងចែកថវិកាសម្រាប់អនុវត្តសកម្មភាពនៅកម្រិត

សាលារៀននេះពិតជាមានសារៈសំខាន់ណាស់ ពីព្រោះសាលារៀនអាចចំណាយបាន ឬមិនបាន គឺអាស្រ័យលើការបែងចែកថវិកានេះ ឲ្យត្រូវទៅតាមអនុគណនីចំណាយនីមួយៗតាមមាតិកាចំណាយថវិកាផងដែរ។ យោងតាមបញ្ហាមួយចំនួនខាងលើ ការបែងចែកថវិការបស់នាយកដ្ឋានជំនាញទៅអនុគណនីមួយចំនួនសម្រាប់អនុវត្តសកម្មភាពនៅសាលាបឋមសិក្សាមិនត្រឹមត្រូវតាមតម្រូវការជាក់ស្តែងរបស់សាលារៀនឡើយ ដូចជាកន្លងមក នាយកដ្ឋានជំនាញមួយចំនួនបានបែងចែកថវិកាសម្រាប់អនុគណនីនៃការប្រើប្រាស់ទឹកនិងភ្លើង ដល់សាលារៀនដែលគ្មានលទ្ធភាពប្រើប្រាស់ ជាហេតុនាំឲ្យថវិកាត្រូវនៅសល់ ហើយមិនអាចផ្ទេរយកទៅចំណាយលើអនុគណនីណាមួយផ្សេងទៀតបានឡើយ។ រីឯសាលារៀនដែលមានតម្រូវការប្រើប្រាស់ប្រព័ន្ធទឹក និងភ្លើង បែរជាគ្មានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយទៅវិញ។ ចំពោះបញ្ហានេះ តើការរៀបចំផែនការបែងចែកថវិកាដល់សាលារៀន នាយកដ្ឋានជំនាញរៀបចំយ៉ាងដូចម្តេច?

បញ្ហាទី៣៖ រយៈពេលនៃការដកសាច់ប្រាក់-បើកផ្តល់-ចំណាយ-រៀបចំឯកសារទូទាត់និងការបញ្ជូនឯកសារទូទាត់។ បញ្ហានេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអនុវត្តថវិកាឲ្យទទួលបានលទ្ធផលខ្ពស់ ពីព្រោះថា រាល់ការចំណាយអនុវត្តសកម្មភាពរបស់អង្គភាពថ្នាក់ក្រោមជាតិ គឺអាស្រ័យលើសាច់ប្រាក់ដែលអង្គភាពថ្នាក់ជាតិទម្លាក់ឲ្យ ប៉ុន្តែប្រសិនបើថ្នាក់ជាតិទម្លាក់សាច់ប្រាក់ឲ្យមិនទាន់ពេលវេលា តើថ្នាក់ក្រោមជាតិ ជាពិសេសសាលារៀន បានអ្វីយកទៅចំណាយអនុវត្តសកម្មភាព? ដូចគ្នាផងដែរ ចំពោះការរៀបចំឯកសារទូទាត់ ប្រសិនបើមិនទាន់បានចំណាយអនុវត្តសកម្មភាពផង តើមានឯកសារមកពីណាដើម្បីរៀបចំទូទាត់? ដូច្នេះចំពោះបញ្ហានេះ តើការទម្លាក់សាច់ប្រាក់ពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិធ្វើឡើងនៅពេលណា? មានរយៈពេលប៉ុន្មានថ្ងៃឬសប្តាហ៍?។ បន្ទាប់សាច់ប្រាក់ត្រូវបានទម្លាក់ តើមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តដកសាច់ប្រាក់នៅពេលណា? ហើយបើកផ្តល់បន្តទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌនៅពេលណា? បន្ទាប់មក ត្រូវចំណាយរយៈពេលប៉ុន្មានថ្ងៃដើម្បីបើកផ្តល់បន្តដល់សាលារៀន?។ ក្រោយពីសាលារៀនបានទទួលសាច់ប្រាក់ តើសាលាត្រូវចំណាយរយៈពេលប៉ុន្មានថ្ងៃឬសប្តាហ៍ដើម្បីអនុវត្តសកម្មភាព? បន្ទាប់មកទៀត តើសាលារៀនត្រូវចំណាយរយៈពេលប៉ុន្មានថ្ងៃឬសប្តាហ៍ដើម្បីរៀបចំឯកសារទូទាត់? ហើយប៉ុន្មានថ្ងៃឬសប្តាហ៍ទៀតដើម្បីបញ្ជូនឯកសារទូទាត់ទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌពិនិត្យ? និងពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។ ជាងនេះទៅទៀត តាមរយៈបញ្ហាដែលបានលើកឡើងខាងលើ ការកែសម្រួលឯកសារទូទាត់ដែលសាលាបានបញ្ជូនឲ្យអង្គភាពពាក់ព័ន្ធពិនិត្យ ហើយត្រូវបានរកឃើញថាមានកំហុស បានចំណាយពេលវេលាជាច្រើនក្នុងការបញ្ជូនឯកសារទៅមកដើម្បីកែកំហុស។ ជាការពិតណាស់ ឯកសារទូទាត់ខុសមួយចំនួនត្រូវបានរកឃើញនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងមួយចំនួនទៀតត្រូវបានរកឃើញនៅកម្រិតមន្ទីរអប់រំ។ ប្រសិនបើបែបនេះ តើត្រូវចំណាយពេល

វេលាប៉ុន្មានថ្ងៃឬសប្តាហ៍ ដើម្បីសាលាយកឯកសារដែលខុសពីការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ ទៅកែ និងប៉ុន្មានថ្ងៃឬសប្តាហ៍ទៀតពីមន្ទីរអប់រំ? ចុះចំណែកសាលាដែលនៅតំបន់ដាច់ស្រយាល ឬជួបការលំបាក តើត្រូវចំណាយពេលវេលាប៉ុន្មានថ្ងៃឬសប្តាហ៍ទៀត? ទាំងនេះនឹងនាំទៅរកការបាត់បង់ពេលវេលាកាន់តែច្រើនឡើងៗ។ ម្យ៉ាងវិញទៀត តើការបើកផ្តល់សាច់ប្រាក់ពីអង្គភាពថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ដល់ការិយាល័យអប់រំយុវន និងកីឡាក្រុង ស្រុក-ខណ្ឌ ហើយពីការិយាល័យអប់រំយុវន និងកីឡាក្រុង ស្រុក-ខណ្ឌដល់សាលារៀនធ្វើឡើងយ៉ាងដូចម្តេច? តាមរយៈប្រព័ន្ធធនាគារ? ឬតាមរយៈការឡើងទៅបើកប្រាក់ដោយផ្ទាល់?

បញ្ហាទី៤៖ ការកសាងសមត្ថភាព។ ការកសាងសមត្ថភាពក៏ជាបញ្ហាសំខាន់មួយផងដែរ ពីព្រោះដើម្បីឲ្យការងារមួយសម្រេចបានដោយជោគជ័យ អ្នកអនុវត្តការងារនោះក៏ត្រូវមានសមត្ថ-ភាពផងដែរ។ ប៉ុន្តែ បញ្ហាដែលមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តតែងតែបានលើកឡើងគឺសមត្ថភាពមន្ត្រីអនុវត្តការងារនៅមានកម្រិត មិនថាតែនៅសាលារៀន ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ និងនៅមន្ទីរអប់រំរាជធានី-ខេត្តឡើយ។ ជាមួយគ្នានេះដែរ ក៏មានការស្នើសុំឲ្យមានការបំប៉ន ឬបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តការងារទាំងនោះផងដែរ។ មន្ត្រីក្រសួងអប់រំ យុវជន និងកីឡាសុទ្ធសឹងតែជាគ្រូបង្រៀន តើនៅតាមសាលារៀនមានជំនាញគណនេយ្យករដែរឬទេ? ហើយក្រសួងអប់រំ យុវជន និងកីឡាជាពិសេសនាយកដ្ឋានជំនាញ និងនាយកដ្ឋានពាក់ព័ន្ធ មានផ្តល់ការបំប៉នឬបណ្តុះបណ្តាលដល់ពួកគាត់ដែរឬទេ? បើមាន តើការបំប៉ននេះធ្វើឡើងប៉ុន្មានដងក្នុង១ឆ្នាំ? ហើយសិក្ខាកាមចូលរួមមានប៉ុន្មាននាក់?

បញ្ហាទី៥៖ គោលការណ៍ ឬនីតិវិធី ណែនាំរបស់អង្គភាពពាក់ព័ន្ធ។ គោលការណ៍ និងនីតិវិធីណែនាំនេះពិតជាមានសារៈសំខាន់ណាស់ក្នុងការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅអង្គភាពថ្នាក់ក្រោមជាតិ ពីព្រោះអង្គភាពទាំងនេះគឺជាអង្គភាពអនុវត្តការចំណាយ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពជំនាញថ្នាក់ជាតិ។ រាល់ការអនុវត្តចំណាយត្រូវផ្អែកលើការណែនាំរបស់អង្គភាពថ្នាក់ជាតិ។ ហេតុដូច្នេះ ការងារគ្រប់គ្រង និងអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ អនុវត្តបានល្អ និងទាន់ពេលវេលា ឬមិនបាន គឺអាស្រ័យទៅលើគោលការណ៍ ឬនីតិវិធីណែនាំទាំងនេះ។ ប្រសិនបើអង្គភាពថ្នាក់ជាតិផ្តល់ការណែនាំឲ្យអនុវត្តបានទាន់ពេល នោះការងារអនុវត្តថវិកាក៏បានទាន់ពេលផងដែរ ប៉ុន្តែប្រសិនបើអង្គភាពថ្នាក់ជាតិផ្តល់ការណែនាំមិនបានទាន់ពេលវេលាទេ នោះការអនុវត្តថវិការបស់អង្គភាពថ្នាក់ក្រោមជាតិក៏ត្រូវបានពន្យាពេលផងដែរ។ កន្លងមក មន្ទីរអប់រំរាជធានី-ខេត្តតែងតែសំណូមពរដល់នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡាជួយអន្តរាគមន៍ដល់នាយកដ្ឋានជំនាញមួយចំនួន ក្នុងការផ្តល់សៀវភៅណែនាំសម្រាប់អនុវត្តថវិកាកម្មវិធីឲ្យបានទាន់ពេលវេលា។ ហេតុអ្វីបានជានាយកដ្ឋានជំនាញផ្តល់ការណែនាំអនុវត្តថវិកាឲ្យអង្គភាពថ្នាក់ក្រោមជាតិមិនទាន់ពេលវេលា? តើមានផលលំបាកអ្វីខ្លះដែលរាំងស្ទះដល់ដំណើរការ

រៀបចំគោលការណ៍ណែនាំទាំងនេះ?។ ម្យ៉ាងវិញទៀត ចំពោះនីតិវិធី និងគោលការណ៍ណែនាំមួយចំនួនក្នុងការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីរបស់ក្រសួងពាក់ព័ន្ធមួយចំនួន តើសមស្រប និងឆ្លើយតបទៅនឹងការចំណាយជាក់ស្តែងរបស់សាលារៀនដែរឬទេ? ដូចជាការផ្តល់ថវិកាសម្រាប់ដំណើរការសាលារៀនដែលនៅតំបន់ដាច់ស្រយាលនិងជួបការលំបាក និងសាលាដែលនៅទីប្រជុំជន។

បញ្ហាទី៦៖ ការចូលរួមរបស់សហគមន៍។ ការចូលរួមរបស់សហគមន៍នេះក៏មានសារៈសំខាន់ផងដែរ ពីព្រោះវាជាតឹកតាងបង្ហាញថា ការគ្រប់គ្រង និងអនុវត្តថវិកា មានតម្លាភាព និងគណនេយ្យភាព ព្រមទាំងអាចបញ្ចៀសផុតពីបញ្ហាទាំងឡាយណាដែលកើតមានឡើងពីការមិនទុកចិត្តគ្នារវាងគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ ក៏ដូចជាសហគមន៍មួយចំនួនផងដែរ។ ការមិនទុកចិត្តគ្នាក្នុងការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនេះ តែងតែកើតមានឡើងចំពោះសាលាមួយចំនួនធំដែលនាយកសាលាច្រើនតែអត្តនោម័តក្នុងការចំណាយថវិកា ព្រមទាំងបិទបាំងអំពីព័ត៌មានសាច់ប្រាក់ដែលសាលាបានទទួល និងបានចំណាយ។ ការណ៍បែបនេះ បានធ្វើឲ្យសហគមន៍មួយចំនួនអស់ទឹកចិត្ត គ្មានទំនាក់ទំនង និងគ្មានជំនឿលើការគ្រប់គ្រងរបស់គណៈ-គ្រប់គ្រងសាលារៀន ព្រមទាំងបដិសេធចូលរួមគ្រប់សកម្មភាពរបស់សាលា។ ជាក់ស្តែង តើមានហេតុផលអ្វីខ្លះទៀតដែលសហគមន៍មិនបានចូលរួមដឹងឮក្នុងការងារគ្រប់គ្រង និងអនុវត្តថវិកានៅសាលារៀន? យោងតាមការសិក្សារបស់ក្រុមពិនិត្យតាមដានការចំណាយសាធារណៈ(PETS)បានបង្ហាញថា ការចូលរួមរបស់សហគមន៍នៅមានកម្រិតទាបនៅឡើយ។ ក្រៅពីនាយកសាលា លោកគ្រូ-អ្នកគ្រូគឺជាអ្នកដែលត្រូវដឹងអំពីការចំណាយថវិកាPAPនេះប្រសើរបំផុត ពីព្រោះពួកគាត់ក៏ជាអ្នកដែលតែងតែលើកយកបញ្ហាថវិកានេះមកចោទជាបញ្ហាផងដែរ។ ជាមួយគ្នានេះដែរ PETS ក៏បានលើកឡើងផងដែរអំពីបញ្ហាដែលធ្វើឲ្យពួកគាត់មិនបានចូលរួម។ PETS បានបង្ហាញថា បុគ្គលិកសិក្សាទាំងនេះមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ចូលរួមដឹងឮពីការចំណាយថវិកា PAPឡើយ ដែល៧០%នៃពួកគាត់មានការងារផ្សេងទៀតក្រៅពីបង្រៀន។ ជាងនេះទៅទៀត គណៈកម្មការទ្រទ្រង់សាលា ក៏មិនសូវបានចូលរួមដឹងឮពីការចំណាយថវិកានៅសាលាផងដែរ ដោយសារបញ្ហាជីវភាព(Kimchoeun, P. 2006)។ ចុះចំណែកបច្ចុប្បន្ន ក្នុងការអនុវត្តថវិកាកម្មវិធី តើលោកគ្រូ អ្នកគ្រូ ក៏ដូចជាសហគមន៍ បានទទួលព័ត៌មានអំពីបញ្ហាថវិកានេះដែរឬទេ? ហើយបានដឹងឮរាល់ការងារគ្រប់គ្រង និងអនុវត្តចំណាយថវិការបស់សាលារៀនដែរឬទេ?

## ៤.២ សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកបញ្ហាទាំងប៉ុន្មានខាងលើនេះពិតជាមានទំនាក់ទំនងគ្នាយ៉ាងពិតប្រាកដមែនចំពោះការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀន ប៉ុន្តែគ្រាន់តែយើងមិនទាន់បានដឹងប្រាកដថាតើបញ្ហាមួយណាដែលជះឥទ្ធិពលខ្លាំងជាងគេទៅលើការងារគ្រប់គ្រង និង

អនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀន គឺដោយសារតែការសិក្សានេះគ្រាន់តែជាការសិក្សាវិភាគទៅលើឯកសារមួយចំនួនដែលប្រមូលបាន មិនទាន់បានចុះធ្វើការប្រមូលទិន្នន័យមកសិក្សាផ្ទាល់នៅឡើយទេ។ ហេតុដូច្នេះ ដំណោះស្រាយពីអង្គភាពពាក់ព័ន្ធមួយចំនួន ក៏ដូចជាសាលារៀនផ្ទាល់នៅពុំទាន់មានចម្លើយមួយណាដែលច្បាស់នៅឡើយដែរ។ ចម្លើយដែលប្រសើរបំផុតគឺជាចម្លើយដែលទទួលបានពីការបកស្រាយដោយផ្ទាល់របស់គណៈគ្រប់គ្រងសាលារៀន លោកគ្រូ-អ្នកគ្រូសហគមន៍ ក៏ដូចជារបស់មន្ត្រីពាក់ព័ន្ធនានាផងដែរតាមរយៈការសម្ភាសន៍។ ជារួម ការសិក្សានេះគ្រាន់តែជាការវិភាគលើរបាយការណ៍របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងគោលការណ៍ណែនាំអំពីនីតិវិធីនៃការអនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀនប៉ុណ្ណោះ មិនមានការវិភាគទៅលើទិន្នន័យទេ។

ចំពោះបញ្ហាមួយចំនួនខាងលើ ដំណោះស្រាយមួយដែលល្អ គឺមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត គប្បីស្វែងរកដំណោះស្រាយមួយដ៏ប្រសើរ ហើយធ្វើការណែនាំទៅដល់ការិយាល័យអប់រំក្រុង ស្រុក-ខណ្ឌឲ្យណែនាំបន្ត ឬណែនាំដោយផ្ទាល់ដល់សាលារៀនលើការងារគ្រប់គ្រង និងអនុវត្តចំណាយថវិកា ជាពិសេសការរៀបចំឯសារទូទាត់ឲ្យបានទាន់ពេលវេលា និងទទួលបានលទ្ធផលល្អដូចបានគ្រោងទុក។ ក្នុងករណីនេះ អ្នកសិក្សាគ្រាន់តែទាញរកនូវដំណោះស្រាយជាបណ្ដោះអាសន្នថាតើភាគីណាដែលអាចដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតឡើងចំពោះមុខជាមុនសិន។ យើងដឹងហើយថា ក្នុងការដោះស្រាយរាល់បញ្ហាដែលកើតមានឡើងទាល់តែមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន និងអង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ នោះទើបការងារប្រសើរឡើង ពីព្រោះបញ្ហាមួយចំនួនថ្នាក់មន្ទីរ ឬនាយកដ្ឋានជំនាញមិនអាចដោះស្រាយបានទេ ទាល់តែមានការអន្តរាគមន៍ពីថ្នាក់ដឹកនាំក្រសួងទើបអាចដោះស្រាយបាន។ ហេតុដូច្នេះអ្នកពាក់ព័ន្ធទាំងអស់គប្បីរួមគ្នាដោះស្រាយបញ្ហាដែលកើតមាន និងខិតខំស្វែងរកវិធានការណ៍ល្អៗនិងសមស្របតាមនីតិវិធិគណនេយ្យ-ហិរញ្ញវត្ថុដើម្បីឲ្យការងារបានប្រសើរឡើង នោះលទ្ធផលនៃការអនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡាក៏ទទួលបានតាមផែនការកំណត់ដែរ ។ ជាមួយគ្នានេះ ដៃគូអភិវឌ្ឍនានាក៏នឹងផ្ដល់ជំនួយដល់វិស័យអប់រំឲ្យកាន់តែប្រសើរជាងបច្ចុប្បន្ននេះទៅទៀត។

បន្ថែមពីនេះ ការសិក្សានេះក៏បានឆ្លុះបញ្ចាំងអំពីការគ្រប់គ្រងអង្គភាពមួយឲ្យបានល្អ មានតម្លាភាព និងគណនេយ្យភាពផងដែរ ពីព្រោះថាវាពិតជាមានសារៈសំខាន់ណាស់។ អង្គភាពមួយដំណើរការងារប្រកបដោយភាពរលូន ឬមិនរលូន បញ្ចៀសបាននូវរាល់បញ្ហាផ្ទៃក្នុងដែលកើតមានឡើងបាន ឬមិនបាន គឺអាស្រ័យលើការគ្រប់គ្រងល្អ និងមិនល្អផងដែរ។ ការគ្រប់គ្រងមួយដែលល្អ គឺទាមទារឲ្យអ្នកគ្រប់គ្រងប្រកាន់ខ្ជាប់នូវគោលការណ៍ជាច្រើនដូចជា អព្យាក្រឹត យុត្តិធម៌តម្លាភាព គណនេយ្យភាព និងភាពស្មោះត្រង់(Sochan.H, 2010)។ ប្រសិនបើបុគ្គលណាម្នាក់បានប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងនេះ បុគ្គលនោះនឹងក្លាយទៅជាអ្នកដឹកនាំ ឬអ្នកគ្រប់គ្រង

មួយរូបដែលល្អ។ នៅគ្រប់ស្ថាប័នទាំងអស់ ទាមទារឲ្យមានបុគ្គលបែបនេះដើម្បីអនុវត្តការងារ ពីព្រោះថាប្រសិនបើការគ្រប់គ្រងរបស់ប្រធានអង្គភាពមិនបានល្អ វានឹងនាំឲ្យមានហានិភ័យ រាំងស្ទះដល់ដំណើរការនៃការអនុវត្តការងាររបស់អង្គភាព។

ជារួម ការគ្រប់គ្រងមួយដែលល្អគឺទាមទារឲ្យមានការធ្វើផែនការ ការអនុវត្តការងារ ការពិនិត្យតាមដាន និងការវាយតម្លៃសកម្មភាពការងារ។ ចំពោះគណៈគ្រប់គ្រងសាលារៀន គួរគិតគូរអំពីផែនការអភិវឌ្ឍសាលា និងការងារបច្ចេកទេសបង្រៀន ឲ្យបានច្រើនជាងការយកថវិកាមកធ្វើជាត្រីមុខ និងសូមបោះបង់ចោលនូវគំនិតអត្តនោម័ត គំនិតទុទ្ទិដ្ឋិនិយម ហើយសូមទទួលយកនូវមតិយោបល់ក្នុងន័យស្ថាបនាកែលម្អពីសំណាក់មជ្ឈដ្ឋានជុំវិញ ជាពិសេសពីបុគ្គលិកក្រោមឱវាទទៅពិចារណា បើល្អសូមទទួលយក ហើយបើគិតថាមិនល្អ សូមបោះបង់ នោះទើបការងារគ្រប់គ្រងអាចទទួលបាននូវជោគជ័យ ពិសេសអាចបញ្ចៀសបាននូវរាល់បញ្ហាដែលកើតមានឡើងបែបនេះ លទ្ធផលនឹងគាប់ប្រសើរ។

## ៤.៣ ការឆ្លុះបញ្ចាំង

តាមរយៈការសិក្សាស្រាវជ្រាវនេះ បានធ្វើឲ្យអ្នកសិក្សាយល់ច្បាស់ថាអ្វីជារបាយការណ៍ស្រាវជ្រាវ និងទម្រង់របស់របាយការណ៍យ៉ាងច្បាស់ដែលកន្លងមកគិតថារបាយការណ៍ស្រាវជ្រាវ (Research Report) នឹងត្រូវពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវដូច Thesis ដែរ។ ប៉ុន្តែពេលនេះបានយល់ច្បាស់ជាងពេលមុនដែលមិនទាន់បានធ្វើការសិក្សា។ ក្រៅពីនេះ បានយល់ច្បាស់ពីការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដើម្បីឲ្យការសិក្សាមួយទទួលបានលទ្ធផលល្អ និងពីការជ្រើសរើសវិធីសាស្ត្របែបណាខ្លះក្នុងការប្រមូលទិន្នន័យ និងវិភាគ។ បន្ថែមពីនេះ អ្នកសិក្សាថែមទាំងអាចចេះសរសេរ និងយល់អំពីរបៀបនៃការសរសេរនូវឯកសារយោងតាមបែប APA ផងដែរ។ ការសិក្សានេះ បើទោះបីមាននូវចន្លោះខ្វះខាតជាច្រើនក៏ដោយ ប៉ុន្តែវាប្រសើរជាងការសរសេរពីមុនដែលសរសេរតាមតែនឹកឃើញឬមើលគំរូតាមឯកសារស្រាវជ្រាវពីមុនៗ។ ប៉ុន្តែឥឡូវនេះ អាចសរសេរបានល្អជាងមុនដោយមិនចាំបាច់ពឹងផ្អែកទៅលើឯកសារអ្នកដទៃទាំងស្រុងឡើយ។ ជាងនេះទៅទៀត ក៏បានយល់គ្រប់គ្រាន់ផងដែរក្នុងការសរសេររំលឹកទ្រឹស្តីដែលជាការដកស្រង់សម្តីរបស់អ្នកស្រាវជ្រាវពីមុន ដែលបានសរសេរទាក់ទងនឹងបញ្ហារបស់ប្រធានបទដែលយើងកំពុងសិក្សាស្រាវ-ជ្រាវបន្ថែម ប៉ុន្តែមិនមែនជាការចម្លងឯកសារស្រាវជ្រាវរបស់គេទាំងដុលនោះទេ ពីព្រោះជាការបំពានសិទ្ធឯកសាររបស់គេ។ លក្ខណៈសម្បត្តិទាំងនេះ គឺទទួលបានពីការខិតខំប្រឹងប្រែងពន្យល់ណែនាំពីសំណាក់លោកបណ្ឌិតដឹកនាំ និងលោកគ្រូអ្នកគ្រូទាំងអស់ដែលបានប្រឹងប្រែងបង្រៀនតាំងពីចាប់ផ្តើមសិក្សារហូតដល់បញ្ចប់ការសិក្សា។ ជាមួយគ្នានេះដែរ ក៏ដោយសារការខំប្រឹងប្រែងរបស់អ្នកសិក្សាផងដែរទើបទទួលបានលទ្ធផលបែបនេះ។

សរុបសេចក្តីមក ការសិក្សាស្រាវជ្រាវនេះពិតជាមានសារៈប្រយោជន៍យ៉ាងខ្លាំងចំពោះ

អ្នកសិក្សាក៏ដូចជាសាលារៀនផងដែរ។ ប៉ុន្តែ អ្វីដែលគួរឲ្យសោកស្ដាយបំផុតនោះ គឺការសិក្សាស្រាវជ្រាវនេះមានទំហំតូចពេក។ ប្រសិនបើមានពេលវេលា និងថវិកាគ្រប់គ្រាន់ ការសិក្សានេះនឹងចុះប្រមូលទិន្នន័យនៅសាលារៀនបឋមសិក្សាឲ្យបានច្រើន ដើម្បីឲ្យការសិក្សាស្រាវជ្រាវនេះកាន់តែមានតម្លៃ និងមានប្រសិទ្ធិភាពជាងការសិក្សាកន្លងមកនេះ ពីព្រោះកន្លងមកពុំសូវមានការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងប្រធានបទនេះឲ្យបានស៊ីជម្រៅច្រើនពេកទេ ដែលជាហេតុធ្វើឲ្យជួបប្រទះនូវឧបសគ្គជាច្រើនក្នុងការប្រមូលទិន្នន័យ និងព័ត៌មានទាំងឡាយដែលទាក់ទងទៅនឹងការរំលឹកទ្រឹស្តី។ លទ្ធផលនេះមិនទាន់គាប់ប្រសើរសោះឡើយ ពីព្រោះព័ត៌មានដែលបានមក គឺភាគច្រើនសុទ្ធតែជារបាយការណ៍នៃការអនុវត្តថវិកាកម្មវិធីរបស់មន្ទីរអប់រំយុវជននិងកីឡារាជធានីខេត្ត និងគោលការណ៍ណែនាំក្នុងការគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចរបស់នាយកដ្ឋានជំនាញមួយចំនួន។

## ៤.៤ ដែនកំណត់និងអនុសាសន៍

ដូចដែលបានជម្រាបជូនខាងលើ ការជ្រើសរើសគំរូ(Sample)សម្រាប់ការសិក្សាស្រាវជ្រាវនេះមានលក្ខណៈតិចតួចស្តួចស្តើងពេកដែលអាចធ្វើឲ្យការសិក្សាវិភាគនេះ ប្រហែលជាមិនសូវទទួលបានលទ្ធផលល្អប្រសើរឡើយ រាល់បទសម្ភាសន៍ដែលធ្វើឡើង មិនប្រាកដថា ចម្លើយដែលទទួលបានពិតទាំងស្រុងនោះទេ ពីព្រោះបញ្ហាថវិកានេះ កន្លងមកគេតែងនិយាយថា ជាចំណុចរសើបមួយដែលអ្នកត្រូវបានគេសម្ភាសន៍មួយចំនួនមិនហ៊ានផ្តល់ចម្លើយពិតឡើយ។ ហេតុដូចនេះ ប្រសិនបើមានអ្នកសិក្សាស្រាវជ្រាវក្រោយៗទៀតមានចំណាប់អារម្មណ៍ចំពោះប្រធានបទនេះ គួរតែជ្រើសរើសយកករណីសិក្សាឲ្យបានច្រើនជាងនេះ គឺនៅគ្រប់រាជធានី-ខេត្តជាការល្អប្រសើរ ពីព្រោះដើម្បីទទួលបានទិន្នន័យកាន់តែច្រើន និងរឹតតែច្បាស់លាស់។ ជាងនេះទៅទៀត អ្នកសិក្សាក្រោយៗទៀត គួរតែស្វែងរកបទពិសោធន៍នៃការអនុវត្តថវិកាកម្មវិធីនេះពីប្រទេសមួយចំនួនដែលបានអនុវត្តកន្លងមក ដើម្បីធ្វើការប្រៀបធៀបជាមួយការអនុវត្តថវិកាកម្មវិធីនេះនៅប្រទេសកម្ពុជាយើង ថាតើការអនុវត្តថវិកានៅប្រទេសដទៃយ៉ាងដូចម្តេច? តើគេមាននីតិវិធីអ្វីខ្លះក្នុងការអនុវត្ត? ម្យ៉ាងទៀត តើការអនុវត្តថវិកាកម្មវិធីរបស់គេបានជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ?ហើយគេមានវិធីសាស្ត្រអ្វីខ្លះក្នុងការដោះស្រាយនូវបញ្ហាទាំងនោះ?។

ចំពោះនីតិវិធី ឬគោលការណ៍ណែនាំ ដែលអង្គភាពជំនាញមួយចំនួនណែនាំឲ្យអង្គភាពអនុវត្តថវិកាកម្មវិធីនៅថ្នាក់ក្រោមជាតិអនុវត្តនោះ នៅមានភាពស្មុគស្មាញនៅឡើយ ជាពិសេសលើមុខចំណាយដែលត្រូវចំណាយ។ ហេតុដូចនេះ គួរនាយកដ្ឋានជំនាញទាំងនោះសិក្សាឲ្យបានច្បាស់ជាមុខសិន សឹមធ្វើការណែនាំឲ្យអង្គភាពក្រោមឱវាទអនុវត្ត ជៀសវាងទម្លាក់សាច់ប្រាក់ឲ្យហើយ អនុវត្តសកម្មភាពមិនកើត។ ម្យ៉ាងវិញទៀត គួរតែនាយកដ្ឋានជំនាញមួយចំនួននោះផ្តល់សៀវភៅ ឬគោលការណ៍ណែនាំទាំងនេះឲ្យថ្នាក់ក្រោមជាតិអនុវត្តឲ្យបានទាន់ពេលវេលា នៅមុន

ពេលដែលមន្ទីរអប់រំបានបើកសាច់ប្រាក់ពីរតនាគាររាជធានី-ខេត្ត។ ការធ្វើបែបនេះ មន្ទីរអប់រំនឹងចំណេញពេលវេលាជាច្រើន ពីព្រោះមន្ទីរនឹងមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំគម្រោងបែងចែកថវិកាទៅឲ្យការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ និងសាលារៀនជាមុន លុះពេលដែលមន្ទីរបានទទួលសាច់ប្រាក់ពីរតនាគាររាជធានី-ខេត្តហើយ មន្ទីរនឹងធ្វើការបែងចែកសាច់ប្រាក់បន្តភ្លាមៗទៅឲ្យការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ និងសាលារៀន អនុវត្តសកម្មភាពការងារបានទាន់ពេល។ ម្យ៉ាងវិញទៀត ចំពោះការបែងចែកថវិកាទៅឲ្យថ្នាក់ក្រោមជាតិអនុវត្ត គួរនាយកដ្ឋានជំនាញមួយចំនួន ដែលកន្លងមកតែងតែជួបបញ្ហាលើអនុគណនីមួយចំនួនដែលមានថវិកាហើយចំណាយមិនបាននោះ សិក្សាឲ្យបានច្បាស់មុននឹងធ្វើការបែងចែកថវិកាឲ្យគេអនុវត្ត ដើម្បីជៀសវាងការសល់។

ដូចគ្នាផងដែរ ចំពោះការកែឯកសារខុសមួយចំនួន គួរការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក-ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត សម្រួល និងអញ្ជើញគណៈនាយក ឬហេរញ្ញិកសាលាមកកែសម្រួលកំហុស និងណែនាំឲ្យពួកគាត់កែ នៅនឹងមន្ទីរ ឬការិយាល័យអប់រំក្រុង ស្រុក-ខណ្ឌដោយផ្ទាល់ មិនចាំបាច់ឲ្យពួកគាត់កាន់ឯកសារចុះឡើងដើម្បីកែសម្រួលកំហុសទាំងនោះទេ។ ការធ្វើបែបនេះ នឹងនាំឲ្យចំណេញពេលវេលាច្រើន ព្រមទាំងបានណែនាំពួកគាត់ដោយផ្ទាល់ ជៀសវាងកំហុសឆ្គងលើកក្រោយទៀត។ ម្យ៉ាងវិញទៀត ចំពោះកំហុសតូចតាចមួយចំនួនដូចជា កំហុសអក្ខរាវិរុទ្ធ គួរតែមន្ទីរ ឬការិយាល័យអប់រំក្រុង ស្រុក-ខណ្ឌជួយសម្រួលកែឲ្យសាលាផង ពីព្រោះសាលាដែលនៅឆ្ងាយ ឬនៅតំបន់ជួបការលំបាក ពិបាកក្នុងការធ្វើដំណើរចុះឡើង។

ចំពោះថវិកាសម្រាប់ដំណើរការសាលារៀន គួរថ្នាក់ដឹកនាំក្រសួង ក៏ដូចជាមន្ត្រីពាក់ព័ន្ធទាំងអស់រួមគ្នាគិតពិចារណារឡើងវិញ អំពីថវិកាឧបត្ថម្ភសម្រាប់ដំណើរការសាលារៀន រវាងសាលាដែលនៅទីប្រជុំជន នៅតំបន់ដាច់ស្រយាលនិងជួបការលំបាក សាលាតូច សាលាមធ្យម និងសាលាធំ ពីព្រោះកន្លងមក សាលាមួយចំនួនបានទទួលសាច់ប្រាក់មិនសមស្របតាមតម្រូវការជាក់ស្តែងនៃការចំណាយ។ ជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំក្រសួង ក៏ដូចជាអង្គភាពពាក់ព័ន្ធទាំងអស់ ក៏គួរពិចារណារិះរកដំណោះស្រាយដ៏សមស្របជួយសម្រួលការងារមួយចំនួនរបស់សាលារៀន ក៏ដូចជាអង្គភាពអនុវត្តថវិកាកម្មវិធីទាំងអស់របស់ក្រសួងអប់រំ យុវជន និងកីឡានូវនីតិវិធីដ៏ស្មុគស្មាញមួយចំនួនដែលអង្គភាពអនុវត្តថវិកាទាំងអស់បានជួបប្រទះកន្លងមក គឺធ្វើយ៉ាងណាដើម្បីឲ្យការអនុវត្តថវិកាកម្មវិធីមានភាពរលូន និងសម្រេចបានតាមគោលដៅកំណត់។

ជាមួយគ្នាផងដែរចំពោះការបើកផ្តល់សាច់ប្រាក់ពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តទៅការិយាល័យអប់រំក្រុង ស្រុក-ខណ្ឌ និងពីការិយាល័យអប់រំ ក្រុង ស្រុក-ខណ្ឌទៅសាលារៀន គួរតែថ្នាក់ដឹកនាំក្រសួង ក៏ដូចជាអង្គភាពពាក់ព័ន្ធគិតពិចារណាប្រើប្រាស់ប្រព័ន្ធធនាគារ

សម្រាប់ប្រតិបត្តិការការផ្ទេរសាច់ប្រាក់នេះ ពីព្រោះវាមានសុវត្ថិភាពជាងការដែលឡើងមកបើកសាច់ប្រាក់ដោយផ្ទាល់។

រីឯបញ្ហានៃការកាត់ភាគរយក្នុងការរត់ឯកសារ ហេតុអ្វីក៏ត្រូវកាត់ភាគរយពីអង្គភាពទាំងនោះ ពីព្រោះ បើយោងតាមការណែនាំរបស់នាយកដ្ឋានជំនាញ ការធ្វើដំណើររបស់បុគ្គលិកអប់រំដែលឡើងទៅរត់ការឯកសារនានាសុទ្ធតែបានផ្តល់របបបេសកកម្មឲ្យ។ តើការកាត់ភាគរយនេះគេយកទៅធ្វើអ្វី? ។ ប្រសិនបើមានការកាត់ភាគរយមែន តើក្នុងមួយសាលារៀន គេកាត់ប៉ុន្មានភាគរយ? ហើយសាលាសល់ថវិកាប៉ុន្មានដើម្បីយកទៅចំណាយអនុវត្តសកម្មភាព?

ដូចគ្នាផងដែរចំពោះការកសាងសមត្ថភាព តើក្នុងមួយអង្គភាពត្រូវបានអញ្ជើញចូលរួមប៉ុន្មាននាក់? ពីព្រោះថាចំនួនសិក្ខាកាមនេះក៏មានសារៈសំខាន់ផងដែរ ជាទូទៅគណៈគ្រប់គ្រងសាលា ឬហេរញ្ញិកសាលាមួយចំនួនបានចូលនិវត្តន៍ ឬរវល់ចេញក្រៅអង្គភាពចូលរួមសិក្ខាសាលានានាច្រើន មិនសូវបាននៅនឹងកន្លែងទេ ជាហេតុនាំឲ្យការអនុវត្តការងារមានការយឺតយ៉ាវ ដូចជាត្រូវរង់ចាំការចុះហត្ថលេខាលើលិខិតស្នើសុំថវិកា លើប័ណ្ណចំណាយ ឬរង់ចាំការឯកភាពពីនាយកសាលាជាដើម។ ហេតុដូចនេះ អង្គភាពពាក់ព័ន្ធគួរតែណែនាំដល់សាលារៀនឲ្យមានអ្នកដែលដឹងអំពីការអនុវត្តការងារ ឬក្រុមការងារយ៉ាងហោចណាស់បីនាក់ដែរ ពីព្រោះនៅពេលដែលម្នាក់ឬពីរនាក់មិននៅ ក៏នៅមានម្នាក់ទៀតដែរដែលអាចអនុវត្តការងារនោះបាន ដូច្នេះ ការងារនឹងមិនស្ទះឡើយ។

ម្យ៉ាងវិញទៀត ចំពោះគណៈគ្រប់គ្រងសាលារៀនមួយចំនួន គួរតែប្រើប្រាស់ថវិកាកម្មវិធីនេះឲ្យចំគោលដៅ និងឲ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ពីព្រោះគោលបំណងធំនៃការដាក់ឲ្យអនុវត្តថវិកាកម្មវិធី ឬថវិកាកម្មវិធីសកម្មភាពជាអាទិភាព(PAP) សម្រាប់វិស័យអប់រំ គឺដើម្បីឲ្យកូនខ្មែរគ្រប់រូបបានចូលរៀនយ៉ាងហោចណាស់ត្រឹមថ្នាក់ទី៩ តាមរយៈការកាត់បន្ថយចំណាយក្រៅផ្លូវការរបស់មាតាបិតាសិស្ស ការចុះឈ្មោះចូលរៀន និងការបង់វិភាគទានគ្រប់រូបភាព។ ប៉ុន្តែ ហេតុអ្វីក៏សាលាមួយចំនួននៅតែមានពិធីបុណ្យផ្កា? តើពិធីបុណ្យនេះធ្វើឡើងដើម្បីអ្វី? តើបច្ច័យបុណ្យនេះគេយកទៅធ្វើអ្វី? ហេតុដូចនេះ សូមគណៈគ្រប់គ្រងសាលាមួយចំនួនកុំអត្តនោម័តក្នុងការចំណាយ សូមកុំយកថវិកាកម្មវិធីនេះជាបញ្ហាធ្វើឲ្យមានភាពល្អក់កករវាងគណៈនាយក និងបុគ្គលិកសិក្សាទាំងអស់ ដោយសារការចំណាយគ្មានតម្លាភាព ជាហេតុធ្វើឲ្យប៉ះពាល់ដល់សតិអារម្មណ៍របស់លោកគ្រូ អ្នកគ្រូមួយចំនួន ហើយពួកគាត់នឹងគ្មានកម្លាំងចិត្តក្នុងការផ្ទេរចំណេះដឹងទៅឲ្យសិស្សានុសិស្ស។ ការណ៍នេះ អ្នកដែលទទួលរងនូវផលប៉ះពាល់ខ្លាំងជាងគេគឺសិស្សានុសិស្ស ពីព្រោះនៅពេលដែលលោកគ្រូ-អ្នកគ្រូមិនសប្បាយចិត្ត ពួកគាត់នឹងជះកំហឹងទៅលើសិស្ស ដោយការមិនចូលបង្រៀនទៅប្រកបរបរថ្មី ឬចូលថ្នាក់រៀនហើយតែមិនបង្រៀនដេរស្តីឲ្យសិស្ស មិនព្យាយាមស្រាវជ្រាវរកអ្វីដែលថ្មីសម្រាប់បង្រៀនសិស្សជាដើម ជាពិសេសការប្រមូលលុយពីសិស្ស។ ទាំងនេះនឹងនាំឲ្យមានការបោះបង់ការសិក្សារបស់សិស្សក្រីក្រមួយ

ចំនួន។ ក៏ដូចគ្នាផងដែរ ចំពោះបុគ្គលិកសិក្សាមួយចំនួន សូមព្យាយាមយល់អំពីការលំបាករបស់គណៈគ្រប់គ្រងសាលាមួយចំនួនដែលពួកគាត់បានចំណាយពេលវេលាច្រើនក្នុងការងារថវិកានេះ ពីព្រោះជានីតិវិធីដែលតម្រូវឲ្យពួកគាត់អនុវត្តតាម ប៉ុន្តែសូមឲ្យមានតម្លាភាពផងដែរ។ម្យ៉ាងវិញទៀត សូមបុគ្គលិកសិក្សាមួយចំនួនកុំផ្តោតសំខាន់លើបញ្ហាថវិកាខ្លាំងពេក សូមមេត្តាគោរពតួនាទី និងគិតអំពីអនាគតកូនខ្មែរយើងឲ្យបានច្រើន ពីព្រោះពួកគេនឹងក្លាយជាទំពាំងស្នងឫស្សីនាពេលអនាគត។ ប្រសិនបើមិននាំគ្នាស្រោចទឹកទំពាំងឲ្យលូតលាស់ទេ តើទំពាំងទាំងនេះអាចក្លាយជាឫស្សីល្អដែរឬទេ? ដូច្នេះ សូមរួមគ្នាផ្ទេរចំណេះដឹង និងបទពិសោធន៍ល្អៗដល់ពួកគេ ដើម្បីឲ្យពួកគេក្លាយជាកូនល្អ ពលរដ្ឋល្អ និងជាសរសរទ្រូងប្រទេសជាតិដ៏រឹងមាំ ក្នុងការអភិវឌ្ឍន៍ប្រទេសឲ្យរីកចម្រើន។ ផ្ទុយទៅវិញ ប្រសិនបើយើងដែលជាអ្នកអប់រំ ជាអ្នកបណ្តុះបណ្តាល ជាអ្នកផ្តល់ពុទ្ធិ និងជាមាតាបិតាទី២ គិតតែពីប្រយោជន៍បុគ្គលនោះ តើអនាគតកូនខ្មែរយើងនឹងទៅជាយ៉ាងណា?

ជារួម ដើម្បីឲ្យការងារគ្រប់គ្រង និងអនុវត្តថវិកាកម្មវិធីនៅកម្រិតសាលារៀនប្រកបដោយប្រសិទ្ធភាពខ្ពស់ អង្គភាពអនុវត្តថវិកាគួរតែ៖ រៀបចំគណៈកម្មការគ្រប់គ្រងថវិកាប្រកបដោយប្រសិទ្ធភាព តម្លាភាពនិងអព្យាក្រឹត រៀបចំផែនការអភិវឌ្ឍសាលារៀន និងផែនការចំណាយថវិកាប្រចាំឆ្នាំឲ្យបានច្បាស់លាស់ ប្រើប្រាស់ថវិកាឲ្យមានតម្លាភាពនិងគណនេយ្យភាព អនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួង ព្រមទាំងពង្រឹងការពិនិត្យតាមដានឲ្យបានល្អ។ បែបនេះ ការអនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា នឹងសម្រេចបានតាមគោលដៅកំណត់ ជាពិសេសដៃគូអភិវឌ្ឍនានានឹងចូលរួមជួយឧបត្ថម្ភដល់វិស័យអប់រំនៅកម្ពុជាកាន់តែច្រើនឡើងៗ។

# ឯកសារយោង


- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១១) *គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី,* ភ្នំពេញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៩) *សារាចរណែនាំបន្ថែម ស្តីពីកិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យ បុរេប្រទាននៅតាមក្រសួង ស្ថាប័ន និងមន្ទីរ-អង្គភាពនៅរាជធានី-ខេត្ត,* ភ្នំពេញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៧) *ប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្ត ថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា,* ភ្នំពេញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៧) *សារាចរណែនាំបន្ថែមលើសារាចរណែនាំ ស្តីពីការចំណាយ តាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន(ថវិកាកម្មវិធី),* ភ្នំពេញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៧) *សារាចរណែនាំបន្ថែមលើសារាចរណែនាំ ស្តីពីការចំណាយ តាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន,* ភ្នំពេញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០៦) *សារាចរណែនាំ ស្តីពីការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន,* ភ្នំពេញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០០០) *សារាចរណែនាំស្តីពីការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព (PAP),* ភ្នំពេញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- រាជរដ្ឋាភិបាល (២០០៨) *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២មូលដ្ឋាននៃថវិកាដែលអាចជឿទុកចិត្តបានឆ្ពោះទៅការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុឲ្យកាន់តែ ប្រសើរឡើង,* ភ្នំពេញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- រាជរដ្ឋាភិបាល(២០០៦) *សារាចរណែនាំ ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់ គ្រងឆ្នាំ ២០០៧,* ភ្នំពេញ ទីស្តីការគណៈរដ្ឋមន្ត្រី។
- រាជរដ្ឋាភិបាល(២០០៤) *កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពង្រឹងអភិបាលកិច្ចល្អ តាមរយៈកំណែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,* ភ្នំពេញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងអប់រំ យុវជន និងកីឡា (២០០៩) *សេចក្តីណែនាំ ស្តីពីមុការអនុវត្តថវិកាកម្មវិធីឆ្នាំ២០០៩របស់ នាយកដ្ឋានបឋមសិក្សា,* ភ្នំពេញ នាយកដ្ឋានបឋមសិក្សា ។
- ក្រសួងអប់រំ យុវជន និងកីឡា (២០០៨) *សេចក្តីណែនាំស្តីពី មុខងារ ភារកិច្ច និងការរៀបចំឯកសារ លិខិតយុត្តិការរបស់អង្គភាពដែលគ្រប់គ្រង និងប្រើប្រាស់ថវិកាកម្មវិធី*

*នៅអង្គភាពកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង,* ភ្នំពេញ នាយកដ្ឋានហិរញ្ញវត្ថុ ។

- ក្រសួងអប់រំ យុវជន និងកីឡា (២០០៨) *ផែនការសកម្មភាព និងការបែងចែកថវិកានៃអនុកម្មវិធីស្តីពីគុណភាព និងប្រសិទ្ធភាពអប់រំនៅបឋមសិក្សា របស់នាយកដ្ឋានបឋមសិក្សា,* ភ្នំពេញ នាយកដ្ឋានបឋមសិក្សា ។
- ក្រសួងអប់រំ យុវជន និងកីឡា (២០០៣) *កម្រងឯកសារស្តីពីគណនេយ្យសាធារណៈ លទ្ធកម្មសាធា- រណៈ កម្មវិធីសកម្មភាពជាអាទិភាព,* ភ្នំពេញ អង្គការ Unicef/Sida ។
- ក្រសួងអប់រំ យុវជន និងកីឡា (២០០០) *កម្មវិធីសកម្មភាពជាអាទិភាពសម្រាប់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំមូលដ្ឋាន,* ភ្នំពេញ នាយកដ្ឋានបឋមសិក្សា ។
- Willson, Kattelus, Hay. (2001). *Accounting for Government and Non-profit entities*, 12th edition, McGraw-Hill Higher Education, New York.
- Kimchoeun, P. (2006). *The Priority Action Programme in Primary Education in Cambodia*, January-March, Volum 10, issue 1, in Cambodia Development Review, Phnom Penh.
- ក្រសួងអប់រំ យុវជន និងកីឡា(២០១១) *សៀវភៅណែនាំស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុថវិកាកម្មវិធី(PB) សម្រាប់អនុវត្តនៅក្រសួងអប់រំ យុវជន និងកីឡា,* ភ្នំពេញ នាយកដ្ឋានហិរញ្ញវត្ថុ
- Rinna, B. (2011). *Application of Student-Centered Approches in Science Subjects in One High School*,Phnom Penh.
- Sochan, H. (2011). *Barriers faced by students in the Master of Education Program at the Royal University of Phnom Penh*, Phnom Penh.

**ឯកសារឧបសម្ព័ន១**

**គំរូលិខិតស្នើសុំដកសាច់ប្រាក់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ....
សាលារៀន: ..........
លេខ:.................

**នាយកសាលា**............

**សូមគោរពជូន**

**លោក/លោកស្រីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ........**

**កម្មវត្ថុ:** សំណើសុំដកសាច់ប្រាក់វជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០... ជុំទី... លើកទី...
ចំនួន....................................រ០០ សរសេរជាអក្សរ(...........................រៀលគត់)។

**យោង:** តារាងបែងចែកថវិការវជ្ជទេយ្យបុរេប្រទាន ថវិកាកម្មវិធី ឆ្នាំ២០... ចុះថ្ងៃទី... ខែ... ឆ្នាំ...
របស់....................

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ដើម្បីដំណើរការសាលារៀនទៅតាមផែនការប្រចាំឆ្នាំ សាលាយើងខ្ញុំស្នើសុំដកសាច់ប្រាក់វជ្ជទេយ្យបុរេប្រទានឆ្នាំ២០... ជុំទី... លើកទី... សម្រាប់ចំណាយលើសកម្មភាព៖

១- ឧបត្ថម្ភប្រាក់បង្រៀនថ្ងៃព្រហស្បត្តិ៍ ចំនួន.......................រ០០
២- ឧបត្ថម្ភសប្រាក់សម្រាប់ប្រជុំបច្ចេកទេស ចំនួន.......................រ០០
៣- .......................................................... ចំនួន.......................រ០០

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានមេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឲ្យសាលា.......................បានដកសាច់ប្រាក់ចំនួន.....................រ០០ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.........................ថ្ងៃទី... ខែ... ឆ្នាំ២០...
នាយកសាលារៀន

**ឯកសារឧបសម្ព័ន្ធ២**

**គំរូលិខិត/ពាក្យស្នើសុំថវិកាចំណាយ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ....
សាលារៀន: ..........

**ខ្ញុំបាទ/នាងខ្ញុំឈ្មោះ............................. ជា..................................**

**សូមគោរពជូន**

**លោកនាយក/លោកស្រីនាយិកា.................................**

**កម្មវត្ថុ:** សំណើសុំថវិកាចំនួន.....................រ០០ សរសេរជាអក្សរ(.....................រៀលគត់)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ ខ្ញុំសូមលោកនាយក/លោកស្រីនាយិកា មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតផ្តល់ថវិកាចំនួន.................រ០០ សម្រាប់ទិញ............ ក្នុងអនុគណនី........ ដើម្បី.................. ដោយក្តីអនុគ្រោះ។

សូមលោកនាយក/លោកស្រីនាយិកាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ..........................ថ្ងៃទី... ខែ... ឆ្នាំ២០...

(ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ)

**ឯកសារឧបសម្ព័ន្ធ៣**

**គំរូនៃប័ណ្ណចំណូល**

**ប័ណ្ណចំណូល**

**អង្គភាព:**.......................

**លេខ:**________

**ប័ណ្ណចំណូល**

ថ្ងៃទី..... ខែ..... ឆ្នាំ២០...

រ

បានទទួលពី:........................................................អង្គភាព............................................

ចំនួនទឹកប្រាក់(សរសេរជាអក្សរ):...........................................................................................

.......................................................................................................................................

អត្ថន័យចំណូល:...................................................................................................................

ចុះក្នុងគណនីឥណទានលេខ:.....................................................................................................

ភ្ជាប់ជាមួយ:............................................................................................សក្ខីប័ត្រដើម។

បានទទួលថ្ងៃទី... ខែ... ឆ្នាំ២០...

| | | |
|---|---|---|
| ប្រធានគណនេយ្យ | គណនេយ្យទូទាត់ | បេឡាធិការ |

**ឯកសារឧបសម្ព័ន្ធ៤**

**គំរូនៃប័ណ្ណចំណាយ**

## ប័ណ្ណចំណាយ

**អង្គភាព:.......................**

**លេខ:**________

**ប័ណ្ណចំណាយ**

ថ្ងៃទី..... ខែ..... ឆ្នាំ២០...

៛

បើកឲ្យលោក:....................................................អង្គភាព...........................................

ចំនួនទឹកប្រាក់(សរសេរជាអក្សរ):..........................................................................

.........................................................................................................................

សម្រាប់ចំណាយក្នុង:..........................................................................................

ចុះក្នុងគណនីបំណុលលេខ:..................................................................................

ភ្ជាប់ជាមួយ:............................................................................សក្ខីប័ត្រដើម។

បានទទួលថ្ងៃទី... ខែ... ឆ្នាំ២០...

ប្រធានអង្គភាព ប្រធានគណនេយ្យ គណនេយ្យទូទាត់ អ្នកទទួលប្រាក់

## ឯកសារឧបសម្ព័ន្ធ៥

## គំរូនៃបញ្ជីបេឡា

### បញ្ជីបេឡា

| ល.រ | សក្ខីប័ត្រ | | បរិយាយ | ចំនួនទឹកប្រាក់ | | |
|---|---|---|---|---|---|---|
| | លេខ | ថ្ងៃខែឆ្នាំ | | ចំណូល | ចំណាយ | នៅសល់ |
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| | | | ខែ.......................... | | | |
| | សមតុល្យដើមគ្រា(យោងទឹកប្រាក់នៅសល់ពីខែមុន) | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | សរុបក្នុងខែនេះ | | | |
| | | | បណ្ដាខែមុន | | | |
| | | | បូកយោងពីដើមឆ្នាំដល់ចុងឆ្នាំ | | | |
| | | | | | | |
| បានបញ្ឈប់បញ្ជីត្រឹមថ្ងៃទី...ខែ...ឆ្នាំ... ដោយមានទឹកប្រាក់នៅសល់ចំនួន(សរសេរជាអក្សរ):.... | | | | | | |
| | | | | ធ្វើនៅថ្ងៃទី..ខែ..ឆ្នាំ. | | |
| | | | | អ្នកធ្វើបញ្ជី | | |
| | | | | | | |
| | | | | | | |
| បានឃើញនិងឯកភាព | | | បានពិនិត្យត្រឹមត្រូវ | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**ឯកសារឧបសម្ព័ន្ធ៦**

**គំរូនៃផែនការអភិវឌ្ឍសាលារៀន**

**ផែនការអភិវឌ្ឍសាលារៀន ឆ្នាំសិក្សា......**

| | | | |
|---|---|---|---|
| សាលា............................ | កម្រង................................. | ក្រុង/ស្រុក/ខណ្ឌ............................ | រាជធានី/ខេត្ត.............................. |

| ១- កុមារទាំងអស់បានចូលរៀន | | | | | | | |
|---|---|---|---|---|---|---|---|
| វត្ថុបំណង | សកម្មភាព | ធនធាន | | | សូចនាករ | អ្នកទទួលខុសត្រូវ | ការត្រួតពិនិត្យ និងវាយតម្លៃ |
| | | មនុស្ស | សម្ភារ | ថវិកា | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| ២- ការសិក្សាប្រកបដោយប្រសិទ្ធភាព | | | | | | | |
| វត្ថុបំណង | សកម្មភាព | ធនធាន | | | សូចនាករ | អ្នកទទួលខុសត្រូវ | ការត្រួតពិនិត្យ និងវាយតម្លៃ |
| | | មនុស្ស | សម្ភារ | ថវិកា | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

| ៣- សុខភាព សុវត្ថិភាព និងការការពារកុមារ | | | | | | | |
|---|---|---|---|---|---|---|---|
| វត្ថុបំណង | សកម្មភាព | ធនធាន | | | សូចនាករ | អ្នក ទទួលខុសត្រូវ | ការត្រួតពិនិត្យ និងវាយតម្លៃ |
| | | មនុស្ស | សម្ភារ | ថវិកា | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

| ៤- ការឆ្លើយតបទៅនឹងយេនឌ័រ | | | | | | | |
|---|---|---|---|---|---|---|---|
| វត្ថុបំណង | សកម្មភាព | ធនធាន | | | សូចនាករ | អ្នក ទទួលខុសត្រូវ | ការត្រួតពិនិត្យ និងវាយតម្លៃ |
| | | មនុស្ស | សម្ភារ | ថវិកា | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

| ៥- ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ | | | | | | | |
|---|---|---|---|---|---|---|---|
| វត្ថុបំណង | សកម្មភាព | ធនធាន | | | សូចនាករ | អ្នក ទទួលខុសត្រូវ | ការត្រួតពិនិត្យ និងវាយតម្លៃ |
| | | មនុស្ស | សម្ភារ | ថវិកា | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**៦- ការគាំទ្រកម្មវិធីប្រព័ន្ធអប់រំ**

| វត្ថុបំណង | សកម្មភាព | ធនធាន | | | សូចនាករ | អ្នកទទួលខុសត្រូវ | ការត្រួតពិនិត្យ និងវាយតម្លៃ |
|---|---|---|---|---|---|---|---|
| | | មនុស្ស | សម្ភារ | ថវិកា | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

ធ្វើនៅ......................ថ្ងៃទី.... ខែ... ឆ្នាំ២០...

នាយកសាលា

បានឃើញ និងឯកភាព

ប្រធានគណៈកម្មការទ្រទ្រង់សាលារៀន

បានឃើញ និងយល់ស្រប

ប្រធានគណៈកម្មការកម្រងសាលារៀន

បានឃើញ និងឯកភាព

ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ

**ឯកសារឧបសម្ព័ន្ធ ៧**

## កម្រងសំណួរសម្រាប់ធ្វើការសម្ភាសន៍មន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡា

**១- ទស្សនៈទូទៅ**

១.១- តើអ្នកយល់យ៉ាងណាចំពោះការអនុវត្តថវិកាកម្មវិធី(PB) នៅសាលាបឋមសិក្សា?

……………………………………………………………………………………………

……………………………………………………………………………………………

១.២- តើការអនុវត្តនេះ ជួបប្រទះនូវបញ្ហាប្រឈមដែរឬទេ?

……………………………………………………………………………………………

……………………………………………………………………………………………

**២- ការបើកផ្តល់ថវិកា៖**

២.១- តើនៅពេលណាដែលមន្ទីរបានបើកសាច់ប្រាក់ចេញពីរតនាគារខេត្ត?

……………………………………………………………………………………………

……………………………………………………………………………………………

២.២- តើមានការលំបាកដែរឬទេក្នុងការបើកសាច់ប្រាក់នេះ? បើមានសូមបញ្ជាក់

……………………………………………………………………………………………

……………………………………………………………………………………………

២.៣- តើនៅពេលណាដែលមន្ទីរបើកផ្តល់សាច់ប្រាក់បន្តដល់ការិយាល័យអប់រំ?

……………………………………………………………………………………………

……………………………………………………………………………………………

២.៤- តើមានការលំបាកដែរឬទេក្នុងការបើកសាច់ប្រាក់បន្តនេះ?

……………………………………………………………………………………………

……………………………………………………………………………………………

**៣- ការទូទាត់ឯកសារ៖**

៣.១- តើមន្ទីរបានទទួលឯកសារទូទាត់ពីការិយាល័យអប់រំនៅពេលណា?បន្ទាប់ពីការបើកផ្តល់សាច់ប្រាក់រួច? ……………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

៣.២- តើការប្រមូលឯកសារទូទាត់សម្រាប់ជុំនីមួយៗមានប៉ុន្មានដំណាក់កាល? សូមបញ្ជាក់ឲ្យបានច្បាស់។……………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

៣.៣- តើការប្រមូលឯកសារទូទាត់ដំបូងត្រូវប្រើរយៈពេលប៉ុន្មានទើបបញ្ចប់?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៤- តើមន្ទីរត្រូវការរយៈពេលប៉ុន្មានក្នុងការពិនិត្យឯកសារទូទាត់?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៥- តើឯកសារដែលត្រូវបានរកឃើញថាខុសមានសមាមាត្រចំនួនប៉ុន្មាន?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៦- តើទាមទារនូវរយៈពេលប៉ុន្មានដើម្បីកែឯកសារដែលពិនិត្យឃើញថាខុស?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៧- តើឯកសារដែលបញ្ជូនយកទៅកែសម្រួល ពេលបញ្ជូនត្រឡប់មកវិញនៅតែមានកំហុសឆ្គងដែរឬទេ? បើមាន តើមានសមាមាត្រចំនួនប៉ុន្មាន?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៨-តើត្រូវទាមទាររយៈពេលប៉ុន្មានទៀត សម្រាប់ឲ្យការិយាល័យអប់រំកែឯកសារដែលខុស?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៩- តើមានផលប៉ះពាល់អ្វីខ្លះដល់ការដកសាច់ប្រាក់បន្តទៀត
នៅពេលដែលការកែឯកសារខុសប្រើរយៈពេលយូរ? សូមបញ្ជាក់។

……………………………………………………………………………………………

……………………………………………………………………………………………

## ឯកសារឧបសម្ព័ន្ធ៨

## កម្រងសំណួរសម្រាប់ធ្វើការសម្ភាសន៍មន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡា

### ១- ទស្សនៈទូទៅ

១.១- តើអ្នកយល់យ៉ាងណាចំពោះការអនុវត្តថវិកាកម្មវិធី(PB) នៅសាលាបឋមសិក្សា?

………………………………………………………………………………………

………………………………………………………………………………………

១.២- តើការអនុវត្តនេះ ជួបប្រទះនូវបញ្ហាប្រឈមដែរឬទេ?

………………………………………………………………………………………

………………………………………………………………………………………

### ២- ការបើកផ្តល់ថវិកា៖

២.១- តើនៅពេលណាដែលការិយាល័យអប់រំបានទទួលសាច់ប្រាក់ពីមន្ទីរ?

………………………………………………………………………………………

………………………………………………………………………………………

២.២- តើមានការលំបាកដែរឬទេក្នុងការបើកសាច់ប្រាក់ចេញពីមន្ទីរ?សូមបញ្ជាក់។

………………………………………………………………………………………

………………………………………………………………………………………

២.៣-តើនៅពេលណាដែលការិយាល័យបើកផ្តល់សាច់ប្រាក់បន្តដល់សាលារៀន?

………………………………………………………………………………………

………………………………………………………………………………………

២.៤- តើមានការលំបាកដែរឬទេក្នុងការបើកសាច់ប្រាក់បន្តនេះ?

………………………………………………………………………………………

………………………………………………………………………………………

### ៣- ការទូទាត់ឯកសារ៖

៣.១- តើការិយាល័យអប់រំបានទទួលឯកសារទូទាត់ពីសាលារៀននៅពេលណា? ក្រោយពេលផ្ទេរសាច់ប្រាក់រួច? ………………………………………………………

………………………………………………………………………………………

………………………………………………………………………………………

៣.២-តើការប្រមូលឯកសារទូទាត់ដំបូងត្រូវប្រើប្រាស់រយៈពេលប៉ុន្មានទើបបញ្ចប់?

………………………………………………………………………………………

………………………………………………………………………………………

៣.៣- តើការិយាល័យអប់រំត្រូវការរយៈពេលប៉ុន្មានក្នុងការពិនិត្យឯកសារទូទាត់?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៤- តើឯកសារដែលត្រូវបានរកឃើញថាខុសមានសមាមាត្រចំនួនប៉ុន្មាន?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៥- តើទាមទារនូវរយៈពេលប៉ុន្មានដើម្បីកែឯកសារដែលពិនិត្យឃើញថាខុស?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៦- តើឯកសារដែលបញ្ជូនយកទៅកែសម្រួល ពេលបញ្ជូនត្រឡប់មកវិញនៅតែមានកំហុសឆ្គងដែរឬទេ? បើមាន តើមានសមាមាត្រចំនួនប៉ុន្មាន?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៧-តើសាលាត្រូវប្រើរយៈពេលប៉ុន្មានដើម្បីកែឯកសារខុស?

……………………………………………………………………………………………

……………………………………………………………………………………………

## ឯកសារឧបសម្ព័ន៩

## កម្រងសំណួរសម្រាប់ធ្វើការសម្ភាសន៍គណៈគ្រប់គ្រងសាលារៀន

### ១- ទស្សនៈទូទៅ

១.១- តើអ្នកយល់យ៉ាងណាចំពោះការអនុវត្តថវិកាកម្មវិធី(PB) នៅសាលារៀន?

……………………………………………………………………………………………

……………………………………………………………………………………………

១.២- តើការអនុវត្តនេះ ជួបប្រទះនូវបញ្ហាប្រឈមដែរឬទេ?

……………………………………………………………………………………………

……………………………………………………………………………………………

### ២- ការបើកផ្តល់ថវិកា៖

២.១- តើនៅពេលណាដែលសាលាបានទទួលសាច់ប្រាក់ពីការិយាល័យអប់រំ?

……………………………………………………………………………………………

……………………………………………………………………………………………

២.២- តើមានការលំបាកដែរឬទេក្នុងទទួលសាច់ប្រាក់នេះ?សូមបញ្ជាក់។

……………………………………………………………………………………………

……………………………………………………………………………………………

### ៣- ការទូទាត់ឯកសារ៖

៣.១-តើសាលាផ្ញើឯកសារទូទាត់ទៅការិយាល័យអប់រំនៅពេលណា?ក្រោយពេលទទួលបានប្រាក់រួច? សូមបញ្ជាក់។

……………………………………………………………………………………………

……………………………………………………………………………………………

៣.២- តើការផ្ញើឯកសារទូទាត់ត្រូវប្រើរយៈពេលប៉ុន្មានដែរ? សូមបញ្ជាក់។

……………………………………………………………………………………………

……………………………………………………………………………………………

៣.៣-តើឯកសារដែលពិនិត្យឃើញថាខុសត្រូវកែសម្រួលវិញមានសមាមាត្រចំនួនប៉ុន្មាន?………………………………………………………………………………

……………………………………………………………………………………………

៣.៤- តើការកែឯកសារខុសត្រូវការរយៈប៉ុន្មាន?

……………………………………………………………………………………………

……………………………………………………………………………………………

៣.៥- តើប្រាក់ដែលបែងចែកទៅតាមអនុគណនីនីមួយៗសមស្របដែរឬទេក្នុងការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន? សូមបញ្ជាក់ឲ្យបានច្បាស់។

……………………………………………………………………………………………

……………………………………………………………………………………………

**៤- ការចូលរួមរបស់សហគមន៍**

៤.១-តើលោក/លោកស្រីបានផ្សព្វផ្សាយព័ត៌មានអំពីថវិកាកម្មវិធីនេះឲ្យសហគមន៍ ឬលោកគ្រូ អ្នកគ្រូបានដឹងដែរឬទេ?

……………………………………………………………………………………………

……………………………………………………………………………………………

៤.២-ក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន តើមានការចូលរួមពីលោកគ្រូ អ្នកគ្រូ សហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀតដែរឬទេ?

……………………………………………………………………………………………

……………………………………………………………………………………………

៤.៣- ចំពោះការអនុវត្តថវិកាកម្មវិធី តើលោក/លោកស្រីបានផ្សព្វផ្សាយឲ្យលោកគ្រូអ្នកគ្រូ ឬសហគមន៍ដឹងឮដែរឬទេ?

……………………………………………………………………………………………

……………………………………………………………………………………………

## ឯកសារឧបសម្ព័ន១០

## កម្រងសំណួរសម្រាប់ធ្វើការសម្ភាសន៍លោកគ្រូ-អ្នកគ្រូ និងសហគមន៍

១- តើលោកអ្នកបានដឹងព័ត៌មានអំពីថវិកាកម្មវិធីដែរឬទេ? ប្រសិនបើបាន តើលោកអ្នកបានទទួលព័ត៌មាននេះប្រភពណា?

……………………………………………………………………………………………………

……………………………………………………………………………………………………

២- តើលោកអ្នកត្រូវបានអញ្ជើញចូលរួមក្នុងការកសាងផែនការអភិវឌ្ឍសាលារៀន និងផែនការថវិកាដែរឬទេ?

……………………………………………………………………………………………………

……………………………………………………………………………………………………

៣- តើសាលាបានផ្ដល់ព័ត៌មានអំពីការអនុវត្តថវិកាកម្មវិធីរបស់សាលាដល់លោកអ្នកដែរឬទេ?

……………………………………………………………………………………………………

……………………………………………………………………………………………………

៤- តើលោកអ្នកយល់យ៉ាងណាដែរចំពោះការអនុវត្តថវិកាកម្មវិធីនេះនៅសាលាបឋមសិក្សា?

……………………………………………………………………………………………………

……………………………………………………………………………………………………

៥- សព្វថ្ងៃនេះ តើលោកអ្នកបានចំណាយអ្វីខ្លះទៅលើការរៀនរបស់កូនៗលោកអ្នក?

……………………………………………………………………………………………………

……………………………………………………………………………………………………